មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ែម តំបន់ទី ៥

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

## ថ្ងៃពុធ ទី១៦ ខែសីហា ឆ្នាំ២០០៦

## ខេត្តបាត់ដំបង

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្រ្តេនឌ្ហ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៊ំម (COPCELPROM) ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក វ៉ន ពន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តបាត់ដំបង

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញអំពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទខេត្តបាត់ដំបង

៥. សេចក្តីផ្សេងៗ

### ១. ចំណាប់អារម្មណ៍ស្វាគមន៍ដោយ លោក ឡារី ស្រ្តេនឌ្ហ (Larry Strange) នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

លោក **លោក ឡារី ស្រ្តេនឌ្ហ** នាយកប្រតិបត្តិ នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានបង្ហាញត្រួសៗថា ហេតុអ្វីបានជាវិទ្យាស្ថាន CDRI រៀបចំកម្មវិធីខប់ដែលនេះឡើង ។ វិទ្យាស្ថាន CDRI គឺជាស្ថាប័នមួយធ្វើការស្រាវជ្រាវដោយឯករាជ្យ ដែលបានស្រាវជ្រាវទៅលើគោលនយោបាយផ្សេងៗ ហើយមិនពាក់ព័ន្ធទៅនិងនយោបាយ ឬ គណបក្សនយោបាយណាមួយឡើយ វិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវទៅលើវិស័យ៥ ដែលជាវិស័យសំខាន់ៗនៅក្នុងការជំរុញឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព ដែលមានដូចជា សេដ្ឋកិច្ច និងអភិវឌ្ឍន៍ ពាណិជ្ជកម្ម ការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍វិស័យកសិកម្មជនបទ ការអភិវឌ្ឍន៍ជីវភាពរស់នៅ អភិបាលកិច្ចប្រកបដោយលទ្ធិប្រជាធិបតេយ្យ កំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន សន្តិសុខមនុស្ស និងការដោះស្រាយទំនាស់ ។ ជាទស្សនៈវិស័យរបស់វិទ្យាស្ថាន CDRI ដើម្បីឱ្យវិស័យទាំង ៥ ដំណើរការប្រកបដោយភាពរលូន និងល្អ យើងត្រូវការចាំបាច់ណាស់នូវការកសាងលទ្ធិប្រជាធិបតេយ្យមួយឱ្យបានរឹងមាំ និងពិតប្រាកដក្នុងប្រទេសកម្ពុជា ដោយមើលឃើញពីសារៈសំខាន់នេះហើយបានជាវិទ្យាស្ថានបានព្យាយាម និងធ្វើការជាមួយភាគីពាក់ព័ន្ធនានា ជាពិសេសរឿងការងារបោះឆ្នោត ដើម្បីធ្វើយ៉ាងណាជំរុញឱ្យមានការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធមិ ដោយគ្មានហិង្សា ព្រមទាំងមានវប្បធម៌នៃការជជែកពិភាក្សា ។

វិទ្យាស្ថាន CDRI មានកិត្តិយស និងសេចក្តីរីករាយណាស់ដែលនៅក្នុងការអនុវត្តន៍កម្មវិធី ទាំងសកម្មភាពរបស់ខ្លួន ដោយទទួលបានការគាំទ្រយ៉ាងពេញទំហឹង និងយ៉ាងសកម្មពីភាគីពាក់ព័ន្ធនានា ជាពិសេសរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ អាជ្ញាធរខេត្ត គជប និងគណកម្មាការរៀបចំការបោះឆ្នោតខេត្តក្រុង អង្គការសង្គមស៊ីវិល និងស្ថាប័នភាគីពាក់ព័ន្ធនានាមួយចំនួន ។

លោកបានថ្លែងអំណរគុណដល់ឯកឧត្តម ប្រាជ ច័ន្ទ អភិបាលខេត្ត និងលោក វ៉ន ពន ដែលជាប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តបាត់ដំបង ដែលបានអនុញ្ញាត និងគាំទ្រចំពោះយន្តការខប់សែលប្រ៊ំមនៅក្នុងខេត្តបាត់ដំបងនេះ ។ ជោគជ័យទាំងឡាយរបស់យន្តការខប់សែល គឺអាស្រ័យដោយមានការចូលរួមយ៉ាងសកម្ម និងផុលផុសពីសំណាក់ អស់លោក លោកស្រី ដែលបានចូល

រួមនៅក្នុងពេលនេះ ។ លោកបានជំរុញឱ្យមានការលើកឡើងនៅបញ្ហាអ្វីៗ ដែលពាក់ព័ន្ធទៅនិងក្តីកង្វល់របស់អ្នកចូលរួម ដែលមាននៅក្នុងខេត្តបាត់ដំបងនេះ ដោយជំរុញឱ្យមានការលើកយកមកពិភាក្សាគ្នាត្រង់ទៅត្រង់មក ដោយបើកទូលាយតែម្តង ។ ហើយលោកក៏សូមជូនពរឱ្យការពិភាក្សាគ្នានេះប្រកបដោយផ្លែផ្កា និងទទួលបានលទ្ធផលជាវិជ្ជមាន ។

## ២. **បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម** (COPCELPROM) **ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការខប់សែល នៃវិទ្យាស្ថាន** CDRI

លោក **ឱក សេរី សោភក្តិ៍** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះលោក Larry Strange ដែលបានមានប្រសាសន៍ប្រកបដោយអត្ថន័យដ៏ទូលំទូលាយចំពោះវិទ្យាស្ថាន CDRI ក្នុងការរៀបចំយន្តការខប់សែល ជាពិសេសខប់សែលប្រ៉ម ។ ខប់សែលពាក្យពេញគឺយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ។ ដោយលោកបានធ្វើការតស៊ូនៅជាយដែនចំនួន ១១ ឆ្នាំ ឃើញការលំបាកវេទនា ការស្លាប់ ការដែលប្រជាពលរដ្ឋត្រូវគេធ្វើបាប ហើយវិនាសហិនហោចដោយសារសង្គ្រាម អស់រយៈពេល២៨ ឆ្នាំ ទម្រាំតែយើងក៏សាងបាន មានទឹកភ្លើង មានផ្លូវ បើយើងគិតត្រឡប់ថយក្រោយវិញ គឺការក៏សាងនេះបានមកដោយលំបាកណាស់ ហើយបើសិនជាមានសង្គ្រាមឡើងវិញម្តងទៀត ការរលាយរហ័សណាស់ មិនចាំបាច់ប្រើពេលច្រើនទេ តែមួយភ្លែតបាត់ទៅវិញអស់ ហើយនិងក្លាយទៅជាយុគសម័យខ្មៅងងឹតឡើងវិញទៀត ។ ដូច្នេះគោលបំណងធំរបស់យើងជំនាន់នេះ និងជាមរតក សម្រាប់ខ្មែរជំនាន់ក្រោយ ធ្វើយ៉ាងណាកុំឱ្យត្រឡប់ទៅអតីតកាលដ៏សោកសៅនោះទៀត ។ លោកចេះតែគិតថា តើធ្វើយ៉ាងណា? នៅពេលដែលបានធ្វើជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ពីឆ្នាំ ១៩៩៣ រហូតដល់ឆ្នាំ ១៩៩៨ ដែលបានរៀបចំជាមួយគាត់តាំងពីឆ្នាំ ១៩៩៤មក គឺរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ យើងគ្រោងបោះនៅឆ្នាំ ២០០០ ប៉ុន្តែ ដល់យឺតយើងជំរុញដល់ឆ្នាំ ២០០២ ទើបបានបោះ ។ ហើយនៅពេលដែលបានបោះរហូតទៅដល់យើងមើលឃើញហើយឆ្នាំ ១៩៩៨, ២០០២ , ២០០៣, ២០០៦ អ៊ុនតាក់រៀបចំឱ្យយើងពី ឆ្នាំ ១៩៩៣ វិទ្យាស្ថាន CDRI បានធ្វើការសិក្សាស្រាវជ្រាវមួយថា ហេតុអ្វីបាន ជានៅឆ្នាំ ១៩៩៨ ការបោះឆ្នោតមានទំនាស់ មានរហូតដល់ការកាប់សម្លាប់ មានរូបភាពមិនល្អនៅទូរទស្សន៍ CNN របស់អាមេរិច ពេញទាំងសកលលោក ធ្វើឱ្យមានរូបភាពកេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជាអាប់ឱននៅក្នុងឆាកអន្តរជាតិ ។

យើងបានរកឃើញទំនាស់មួយចំនួន ដែលជាទំនាស់ស៊ីជម្រៅ ហើយលោកចេះតែគិតថាធ្វើយ៉ាងម៉េចដើម្បីដោះស្រាយរឿងទាំងអស់នេះបាន ហើយដោះស្រាយទម្លាប់នៅក្នុងសង្គមខ្មែរយើង ដែលនៅមុខគ្នាយើងគួរសមជាមួយនិងគ្នា យើងមិនសូវលើកបញ្ហាយើងច្រើនតែបញ្ចៀសបញ្ហា ប៉ុន្តែនៅក្រោយខ្នងគ្នាគឺយើងនិយាយចាស់ដៃតែម្តង ។ អញ្ចឹងបានជាលោកគិតថាទំនាស់អ្វីៗដែលកើតឡើងគឺ សុទ្ធតែការមិនយល់គ្នា ការដែលបកស្រាយទៅតាមចិត្តរបស់ខ្លួន ការដែលមិនស្តាប់គ្នាទៅវិញទៅមក ការដែលមិនព្រមលើកបញ្ហាទាំងអស់មកដាក់លើតុ ហើយជជែកគ្នាដោយត្រង់ទៅត្រង់មក ។ ក្នុងគំនិតនេះបានជាយើងចាប់ផ្តើមគិតថាគួរតែមានយន្តការមួយ បើសិនជាយើងមូលគ្នាថា យើងលេងល្បែងប្រជាធិបតេយ្យមែន យើងគួរតែមានយន្តការមួយដើម្បីនិងបង្ការទំនាស់ យើងមិនបានបង្ការទំនាស់បាន ១០០% ទេ ហើយយើងក៏មិនបានជជែកគ្នា ហើយយើងយល់គ្នា យល់ព្រមទាំងអស់គ្នាដែរ ប៉ុន្តែបើសិនជាយើងមានឱកាសជជែកគ្នា យល់គ្នាទៅវិញទៅមក យ៉ាងហោចណាស់ក៏យើងបានយល់ថា ហេតុអ្វីបានជាអ្នកដ៏ទៃឯទៀតគេមិនឯកភាពជាមួយយើង ហេតុអ្វីបានជាជំហរបស់គេខុសឆ្ងាយពីយើង ការយល់គ្នានេះហើយដែលធ្វើឱ្យយើងទំនាក់ទំនង ហើយបន្តការកសាងនូវ

វប្បធម៌ជជែកពិភាក្សាគ្នាទុកចិត្តគ្នា ហើយដោះស្រាយបញ្ហាជាមួយគ្នា ព្រោះបើសិនជាមិនជជែកគឺប្រើកម្លាំងហើយ អស់ពីប្រើដៃគឺប្រើអាវុធ តែការប្រើអាវុធ អ្វីដែលយើងខំកសាងមកជាង ១០ ឆ្នាំនិងរលត់រលាយទៅម្តងទៀត ។

អញ្ចឹងហើយបានជាយន្តការខប់សែលនេះបានបង្កើតឡើងនៅថ្នាក់ជាតិ ពីឆ្នាំ ១៩៩៩ រហូតដល់ឆ្នាំ២០០៣ យើងជំនុំគ្នា ៥០ ដងមួយខែម្តងមិនដែលខានទេ ទោះជាភ្លៀងទឹកលិចក៏ដោយ។ ដល់យើងធ្វើបាន៥០ ដងអញ្ចឹងទៅបានយើងចាប់ផ្តើមគិតថាគណបក្សនយោបាយធំៗទាំង៣ អង្គការសង្គមស៊ីវិល គជប គណបក្សនយោបាយទាំងអស់ សហគមន៍អន្តរជាតិ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង៤ទៀត បានចូលរួមប្រជុំ ដូច្នេះហើយបានជាយន្តការនេះចាប់ផ្តើមឡើង ។ យន្តការនេះគឺធ្វើដោយដៃរបស់ខ្មែរសុទ្ធសាធ មិនបានយកមេរៀនពីណាមកទេ នៅពេលដែលបានគូសវាសយន្តការនេះ ឡើងគឺដោយចិត្តចង់បង្កើតឱ្យមានវប្បធម៌នៃការពិភាក្សាគ្នាកសាងទំនុកចិត្តគ្នា ដោយសារបានឃើញការវិនាសខ្លោចផ្សារ ហើយ១១ ឆ្នាំ នៅជាយដែន លោកឃើញគេធ្វើបាបប្រជាពលរដ្ឋខ្លាំងណាស់ ពិបាកនិងទ្រាំមើលណាស់ ។ ដល់ធ្វើបានជោគជ័យអញ្ចឹងទៅ លោកគិតថា ចប់ហើយនៅឆ្នាំ ២០០៣ ក៏ប៉ុន្តែដល់ពេលដែលយើងរៀបចំការបោះឆ្នោត ២០០៧-២០០៨ អង្គការសហប្រជាជាតិ ជាពិសេស លោក Douglas Gardner ដែលទើបតែមកថ្មីគាត់បានមើលសេចក្តីរាយការណ៍ហ្នឹង គាត់បានអាននៅញូវយ៉ក ហើយបានមកភ្នំពេញ គាត់ថាយន្តការនេះល្អណាស់ ហើយក៏បានមកជួបលោក Larry Strange និងរូបលោក សូមឱ្យធ្វើបន្តទៅទៀត ព្រោះយន្តការបែបនេះមិនមានទេ នៅក្នុងសកលលោក ជាពិសេសនៅប្រទេសដែលចេញពីសង្រ្គាមយូរអង្វែង ហើយចេះបង្កើតយន្តការជជែកពិភាក្សាគ្នាដោយខ្លួនឯង ព្រោះថាវាជាមេរៀននៃការរៀនសូត្រ មិនមែនគ្រាន់តែជាមេរៀនសម្រាប់ប្រទេសកម្ពុជាទេ គឺជាមេរៀនសម្រាប់ប្រទេសថ្មីៗ ដែលទើបតែចេញពីសង្រ្គាមដូចយើងដែរ ។ អញ្ចឹងហើយបានជា UNDP សុំឱ្យយើងធ្វើបន្ត ៣ឆ្នាំទៀត ពីឆ្នាំ ២០០៦ ដល់ ២០០៨ ដូច្នេះយើងក៏ចាប់ផ្តើម ដំណាក់កាលទី២ នេះ ។ ក៏ប៉ុន្តែលោកក៏គិតពិចារណាទៀតថា កាលមុនយើងធ្វើតែនៅថ្នាក់ជាតិ ប៉ុន្តែលើកនេះដល់យើងយកទំនាស់ យកមកវិភាគស៊ីជម្រៅឃើញទំនាស់ដែលខ្លាំងក្លាសស្រាក់សស្រាំ គឺកើតនៅថ្នាក់មូលដ្ឋាន ហើយកាលដែលដោះស្រាយមិនរួចនៅថ្នាក់មូលដ្ឋានធ្វើឱ្យរឿងហ្នឹងក្លាយទៅជារឿងនយោបាយ ដូច្នេះហើយបានលោករំកិលយន្តការ នៅថ្នាក់ជាតិមកថ្នាក់ខេត្ត ទើបបានជាមា ខប់សែលប្រ៊ុមនេះ ។

យើងគិតថាពីនេះទៅទល់និងខែកក្កដាឆ្នាំ ២០០៧-២០០៨ យើងនឹងរៀបចំមួយខេត្តក្រុង ២ដង ជំនុំបែបនេះ ។ នៅខេត្តបន្ទាយមានជ័យ នៅក្រុងប៉ៃលិន យើងមិនដែលឃើញ គឺថាជជែកគ្នារឿងនយោបាយខ្លាំងមែនទែន ប៉ុន្តែជជែកគ្នាមានឥរិយាបថទន់ភ្លន់ សំដីរឹងយោបល់ខ្លាំងមែន ប៉ុន្តែឥរិយាបថគោរពគ្នាទៅវិញទៅមក ថ្លៃថ្នូរជាអ្នកដែលប្រកាន់នូវលិទ្ធិប្រជាធិបតេយ្យមែន ។ រូបលោក ផ្ទាល់ និង លោក Larry Strange រំភើបណាស់ ជាពិសេសទឹកដីប៉ៃលិន ដែលជានិមិត្តរូបនៃសង្រ្គាមអាចនិងធ្វើឱ្យទៅជាដូច្នេះបាន ។ ហើយខេត្តឯទៀតដែលខប់សែលបានឆ្លងកាត់នៅទិសខាងត្បូង និងនៅឥសានគឺសុទ្ធតែដូចគ្នាទាំងអស់ ដូច្នេះ ហើយបានជាយើងធ្វើរឿងនេះឡើង ។ យើងដឹងហើយថាទំនាស់កើតឡើងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតនៅដំណើរការ បោះឆ្នោតតាំងពីចុះឈ្មោះបោះឆ្នោត រហូតដល់ដោះស្រាយពាក្យបណ្តឹង ក្រោយពីប្រកាសលទ្ធផលនៃការបោះឆ្នោតហើយ ប៉ុន្តែយើង មានគោលបំណង៣ធំៗ

**ទី១.** ធ្វើយ៉ាងណាឱ្យការចុះឈ្មោះបោះឆ្នោតក្លាយទៅជាយន្តការដូចយើងដកដង្ហើម ស្លៀកពាក់ ញុំាបាយអញ្ចឹង ទៅអនាគតលោកបានស្រម័យឃើញថាប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ ឆ្នាំ គឺគាត់ដើរទៅស្មៀនឃុំសង្កាត់ក្រុមប្រឹក្សាឃុំសង្កាត់ ហើយចុះឈ្មោះតែម្តង លែងឱ្យការចុះឈ្មោះនៅជាបញ្ហាទៀតហើយ។ នៅស្រុកគេ តែអាយុ ១៨ ឆ្នាំមានកាតមានអត្តសញ្ញាណប័ណ្ណ ទៅចុះ

ឈ្មោះជារឿងធម្មតា មិនត្រូវឱ្យបញ្ហាហ្នឹងនៅជាបញ្ហាទំនាស់កើតបានទៀតទេ ដូច្នេះយើងត្រូវធ្វើយុទ្ធនាការយ៉ាងណា ដើម្បីឱ្យការចុះឈ្មោះនេះ ក្លាយទៅជាយន្តការមួយប្រចាំថ្ងៃរបស់យើងតែម្តង ទៅអនាគត ទោះបីយើងមើលមិនទាន់បានភ្លាម ប៉ុន្តែបើយើងធ្វើការសស្រាក់សស្រាំ ជាមួយគ្នា នឹងអាចទៅជា អញ្ចឹង ។

**ទី២.** ធ្វើយ៉ាងណាឱ្យអត្តសញ្ញាណប័ណ្ណជាតិបានដល់ដៃប្រជាពលរដ្ឋខ្មែរគ្រប់គ្នាទាំងអស់ ចំពោះអ្នកដែលមានអាយុ ១៨ ឆ្នាំឡើងគឺត្រូវតែបានដល់ដៃ កុំឱ្យមានបញ្ហាយកលុយកាក់ កុំឱ្យយកបញ្ហាហ្នឹងទៅជាថ្នូ ទាល់តែអ្នកឯងចូលជាមួយខ្ញុំបានខ្ញុំឱ្យប័ណ្ណឬមួយមានបញ្ហារឿងសញ្ជាតិកើតឡើង គឺថាយើងដោះស្រាយបញ្ហាហ្នឹងជាមួយគ្នា ។ អញ្ចឹងហើយបានជាយើងរំភើបណាស់នៅពេលដែលយើងដាក់បញ្ហានៅលើតុជជែកគ្នាជាប់ៗគ្នា ដោយហេតុនេះហើយបានជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី លោកអានសេចក្តីរាយការណ៍ហ្នឹងទៅ យល់ថាយើងត្រូវតែដោះស្រាយបញ្ហាហ្នឹងហើយ អញ្ចឹងហើយបានជាដើមឆ្នាំ២០០៦ លោករៀបចំនៅយុទ្ធនាការឆ្នាំ ២០០៦ នេះ ដើម្បីឱ្យអត្តសញ្ញាណប័ណ្ណជាតិបានដល់ប្រជាពលរដ្ឋខ្មែរដែលមានចំនួន ១លាន៩សែន នាក់ ឱ្យបានគ្រប់ៗគ្នាតែម្តង ។ នៅខេត្តបន្ទាយមានជ័យធ្វើបាន ៧៦% ហើយគាត់គិតថាដល់ខែធ្នូ នឹងបានក្បែរ១០០% ។ ឆ្នាំនេះមួយខេត្តៗច្រើនបានគ្រប់គ្នា ហើយយើងប្រហែលជានឹងបានស្តាប់របាយការណ៍របស់លោកខាងស្នងការ ដើម្បីដឹងថាខេត្តបាត់ដំបងបានដល់កម្រិតណាហើយ ។

**ទី៣.** ចង់ឃើញយន្តការខប់សែលនេះចូលរួមធ្វើយ៉ាងណាឱ្យដំណើរការបោះឆ្នោតនៅប្រទេសកម្ពុជា ថ្នាក់ឃុំក៏ដោយ ថ្នាក់ជាតិក៏ដោយ ឆ្នាំ២០០៧-២០០៨ ហើយដល់ទៅថ្ងៃមុខទៅយើងនៅមានការបោះឆ្នោតច្រើនទៀត គឺការបោះឆ្នោតក្រុមប្រឹក្សាខេត្ត ការបោះឆ្នោតក្រុមប្រឹក្សាស្រុក ដែលច្បាប់វិមជ្ឈការ និងសហមជ្ឈការ កំពុងតែសរសេរ និងកំពុងតែពិនិត្យសព្វថ្ងៃនេះ ដែលសភាអនុម័តនៅចុងឆ្នាំនេះ ឬមួយដាក់នៅដើមឆ្នាំក្រោយ ។

យើងបោះឆ្នោតច្រើនណាស់ ដូច្នេះយើងចង់ឱ្យយន្តការនៃការបោះឆ្នោតក្លាយទៅជាទម្លាប់ប្រជាធិបតេយ្យមួយរបស់យើងឥឡូវជាពិសេសរបស់កូនខ្មែរនៅថ្ងៃក្រោយឱ្យលែងមានបញ្ហាអសន្តិសុខ បញ្ហាយប់ឡើងឆ្កែព្រូស ការគំរាមកំហែង ការរើសអើង ហើយរឿងអ្វីទៀតជៀសចេញពីយន្តការនៃការបោះឆ្នោតទៅ ។ នេះបានយើងអាចថែរក្សានូវអ្វីដែលយើងបាន កសាងរួមគ្នាអ្វី ដែលប្រជាពលរដ្ឋខ្មែរកសាង ផ្លូវទឹក ផ្លូវថ្នល់ បឹងបួរស្រែ ភ្លើង របស់យើងទាំងប៉ុន្មានឱ្យនៅឋិតថេរ ឱ្យលែងរត់ទៅនៅ ស្រុកគេទៀត។ ដូចលោក Larry Strange បានមានប្រសាសន៍អម្បាញ់មិញហើយ គឺយន្តការខប់សែលបានបង្កើតឡើងដោយដៃ របស់យើងផ្ទាល់ ដោយមិនមានគំនិតមកពីខាងក្រៅទេ យើងមានមោទនៈភាពណាស់ ក៏ប៉ុន្តែអ្នកពិតប្រាកដដែលធ្វើឱ្យយន្តការ ខប់សែលជោគជ័យ មិនមែនខ្ញុំ មិនមែន លោក Larry Strange មិនមែនវិទ្យាស្ថាន CDRI គឺអ្នកដែលចូលរួមហ្នឹងឯង ។ យើងទៅ ខេត្តណាក៏ដោយ ឯកឧត្តមអភិបាលខេត្ត គ្រប់ខេត្តទាំងអស់តែងតែផ្តល់នៅសំបុត្រអនុញ្ញាតភ្លាមៗ លោកចុះហត្ថលេខាភ្លាមៗ ព្រោះដឹងថាយន្តការនេះជួយឱ្យមានវប្បធម៌នៃការជជែកពិភាក្សាគ្នា ជាពិសេសអស់លោក លោកស្រី ទាំងអស់ដែលបានចូលរួមធ្វើឱ្យយន្តការនេះទទួលបានជោគជ័យ ។

## ៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក វន ពន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តបាត់ដំបង

លោក **វន ពន** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត បានបង្ហាញនៅរបាយការណ៍ដោយលើកយកចំណុចសំខាន់ៗនៃ ការបោះឆ្នោតរយៈការកន្លងមក ។ លោកបានមានប្រសាសន៍ថាចាប់តាំងពីយើងចុះហត្ថលេខាកិច្ចព្រមព្រៀងទីក្រុងប៉ារីស

ថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩៦ មកប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតចំនួន ៥ លើក គឺបោះឆ្នោតសកល និងអសកល ការបោះឆ្នោតសកលមាន ៤លើក ទី១ នៅថ្ងៃ ទី ២៣ ខែឧសភា ឆ្នាំ ១៩៩៣ គឺការបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក់ ទី២ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា អណតិទី២ ធ្វើនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៩៨ ដែលរៀបចំឡើងដោយ គជប ទី៣ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ អណ្តិតទី១ ធ្វើនៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០២ ដែលរៀបចំឡើងដោយ គជប ដែរ ទី៤ ការបោះឆ្នោតសកលដែរគឺការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភាអណតិទី៣ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៣ ដែលរៀបចំឡើងដោយ គជប ដែរ ។ ដោយឡែកការ បោះឆ្នោតអសកលយើងបានអនុវត្តនបានមួយលើក នៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៦ គឺការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរៀបចំឡើងដោយ គជប ។ ពីការបោះឆ្នោតមួយ ទៅការបោះឆ្នោតមួយយើងសង្កេតឃើញថាមានការរីកចំរើនយ៉ាងខ្លាំង ការ គ្រប់គ្រង ការដឹកនាំរបស់អាជ្ញាធរបោះឆ្នោត និងអាជ្ញាធរដែន ដីនៅគ្រប់លំដាប់ថ្នាក់ ក្នុងនោះដែលមានការរីកចំរើនចំពោះអ្នកចូលរួម ឬភាគីដែលពាក់ព័ន្ធ ដូចជាគណបក្សនយោបាយ អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលជាដើម ។ ប៉ុន្តែលោកបានជម្រាបថា ការបោះឆ្នោតនីមួយៗគឺមានដំណាក់កាលរបស់វា លោកសូមចែកជា ៣ដំណាក់កាលសំខាន់ៗ:

**ទី១.** គឺជាដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត ក្នុងដំណាក់កាលនេះពីឆ្នាំ ១៩៩៨ មករហូតដល់ឆ្នាំ ២០០៦ នេះ គជប បានធ្វើការកែទម្រង់នីតិវិធីជាបន្តបន្ទាប់ ។ ឧទាហរណ៏ នៅឆ្នាំ១៩៩៨ ដើម្បីចុះឈ្មោះបោះឆ្នោត គជប បានបង្កើតក្រុមមួយហៅថាក្រុមចុះឈ្មោះបោះឆ្នោត ឬ RSO ឬ REC ក្រុមចុះឈ្មោះបោះឆ្នោតនេះគឺចុះឈ្មោះបងប្អូនប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំ ឡើងទៅអាចចុះឈ្មោះបាន ប៉ុន្តែចុះឈ្មោះនៅកន្លែងណាគាត់ត្រូវទៅបោះឆ្នោតនៅកន្លែងនោះ សម័យនោះយើងប្រើប័ណ្ណបោះឆ្នោតសម្រាប់ បញ្ជាក់អត្តសញ្ញាណ ដើម្បីទៅបោះឆ្នោត ព្រោះថាយើងទើបងើបចេញពីសង្គ្រាមយើងមិនមានអត្តសញ្ញាណប័ណ្ណ ឬកាត ឬលិខិតសំគាល់ខ្លួនទេ យើងមានអត្តសញ្ញាណប័ណ្ណដែលមានបិទរូបថតនៅទីនោះ ហើយអត្តសញ្ញាណប័ណ្ណនេះ បងប្អូនយើងអាចយកទៅប្រើប្រាស់ ដើរបានទូទាំងប្រទេសនៅសម័យនោះ។ ប៉ុន្តែមកដល់ឆ្នាំ ២០០១ យើងបានធ្វើការចុះឈ្មោះបោះឆ្នោតដែរ ប៉ុន្តែ គជប បានធ្វើប្រតិភូកម្មអំណាចជូនដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០១ គឺក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្មៀនឃុំគាត់ជាមន្ត្រីចុះឈ្មោះបោះឆ្នោតនៅក្នុងត្រីមាសទី ៤ នៃដំណាច់ឆ្នាំនីមួយៗ គឺចាប់តាំងពីថ្ងៃទី ១ ខែតុលា រហូតទៅដល់ ថ្ងៃទី ៣១ ខែធ្នូ នោះគឺជូនបញ្ហានេះ ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្មៀនឃុំ ជាមន្ត្រីចុះឈ្មោះបោះឆ្នោត ។ ពីរដំណាក់កាលនេះ ដំណាក់កាលនៃការបង្កើតក្រុមចុះឈ្មោះបោះឆ្នោត និងដំណាក់កាលនៃការធ្វើប្រតិភូកម្មអំណាចជូនដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ឱ្យគាត់ធ្វើជាមន្ត្រីបោះឆ្នោត គឺការចុះឈ្មោះបោះឆ្នោតរបស់យើង មានបញ្ហាជាហូរហែរ គឺមានបញ្ហាទំនាស់ពីរឿងសញ្ជាតិ អាយុជាដើម ។

ដោយមើលឃើញបញ្ហានេះ គជប បានធ្វើការកែទម្រង់មួយទៀត គឺបំណាច់ឆ្នាំនីមួយៗយើងធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ ប៉ុន្តែក្រុមប្រឹក្សាឃុំនៅតែដើរតួនាទីជាមន្ត្រីចុះឈ្មោះដដែល ។ ដំណាក់កាលទាំងពីរនេះយើងសង្កេតឃើញថាមានការលំបាកច្រើនចំពោះអ្នកបោះឆ្នោត ខ្លះគាត់ថាទៅរកកន្លែងបោះឆ្នោតមិនឃើញ ខ្លះគាត់ថាមិនដឹងថាទីតាំងការិយាល័យនៅឯណា ខ្លះថាមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នេះជាបញ្ហាមួយដែលធ្វើឱ្យយើងមានការលំបាកចំពោះអ្នកបោះឆ្នោត ។ អញ្ចឹងហើយ គជប ដើម្បីសម្រួលដល់ការងារនេះ បានជាឆ្នាំ ២០០៦ នេះ យើងឈានមកដល់ធ្វើការសាកល្បងចែកប័ណ្ណព័តិមានសម្រាប់អ្នកបោះឆ្នោត ដែលមានគោលបំណងដូចតទៅ

ពីមុនអ្នកបោះឆ្នោតគាត់ថារកទីតាំង ឈ្មោះ លេខការិយាល័យ មិនឃើញ អញ្ចឹងការចែកប័ណ្ណនេះ គឺជាព័តិមានមួយដោយផ្ទាល់ដល់អ្នកបោះឆ្នោតឱ្យគាត់មើលឈ្មោះរបស់គាត់ ឈ្មោះអី ថ្ងៃ ខែ ឆ្នាំកំណើត នៅការិយាល័យណា ត្រូវបោះឆ្នោតនៅកន្លែងណា

លេខរៀងទីប៉ុន្មាន នៅក្នុងបញ្ជីបោះឆ្នោត គឺសម្រាប់សម្រួលហើយនៅខាងក្រោយប័ណ្ណបោះឆ្នោតមានដាក់ ថ្ងៃ ខែ ឆ្នាំ ដែលត្រូវបោះឆ្នោត គឺទី១ ជាការសម្រួលដល់អ្នកបោះឆ្នោត ទី២ សម្រាប់អ្នកបោះឆ្នោតបានឃើញឈ្មោះគាត់ ហើយគាត់អាចមើលឈ្មោះថា ត្រូវ ឬខុស នៅក្នុងអត្តសញ្ញាណប័ណ្ណរបស់គាត់ ។ អញ្ចឹងចែកប័ណ្ណមានផលប្រយោជន៍សំខាន់ ដំណាក់កាលទី ១ សម្រាប់ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅខែ តុលានេះ ដំណាក់កាលទី ២ ចែកប័ណ្ណនេះសម្រាប់ទៅបោះឆ្នោតផ្ទាល់តែម្តង គឺបោះឆ្នោតនៅថ្ងៃទី ១ ខែមេសា ឆ្នាំ ២០០៧ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ។ ការសាកល្បងទី១ យើងធ្វើនៅក្នុងខែមិនា និងខែមេសា ឆ្នាំ ២០០៦ គឺយើងសាកល្បងទូទាំងប្រទេសធ្វើតែ ១០ ឃុំទេ ដែលនៅខេត្តបាត់ដំបងបានសាកល្បងនៅឃុំសិរីមានជ័យ ស្រុកសំពៅលូន ។ ការសាកល្បងនេះយើងចង់ដឹងថាតើការលំបាកយ៉ាងម៉េចខ្លះ ដើម្បីឈានទៅធ្វើការចែកប័ណ្ណនៅពេលដែលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០៧ និងការបោះឆ្នោតផ្សេងៗទៀត ។ ធ្វើទៅ១០ ឃុំ នៅទូទាំងប្រទេស យើងបូកសរុបមកថាការលំបាកយ៉ាងម៉េចបានជានៅក្នុង ខែសីហា នេះ ឈានទៅដល់ការចែកប័ណ្ណព័ត៌មាន ជូនដល់អ្នកបោះឆ្នោត ដើម្បីធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅដំណាច់ឆ្នាំ ២០០៦នេះ ។ ឥឡូវនេះខេត្តបាត់ដំបងកំពុងតែអនុវត្តបានកន្លះខែហើយ ដែលការអនុវត្តនេះទទួលបានលទ្ធផលមិនសូវបាន ល្អទេដោយសារព័ត៌មានយើងយកបានតែ ៥៥ ឃុំទេ មកដល់ថ្ងៃនេះ អញ្ចឹងបានជាយើងលោក នឹងធ្វើការចុះទៅផ្ទាល់ជាមួយគ្រប់ឃុំនៅក្រោយ ដើម្បីរៀបចំព័ត៌មាននេះឱ្យបានច្បាស់លាស់ នេះគឺជាដំណាក់កាលនៃការចុះឈ្មោះ ។

**ទី២.** គឺជាដំណាក់កាលនៃការឃោសនាបោះឆ្នោត ដែលជាដំណាក់មួយក្តៅគគុក និងងាយរលាកទៀត អញ្ចឹងបណ្តឹងទាំងឡាយ ទំនាស់ទាំងឡាយ គឺលេចចេញមកពីការឃោសនាបោះឆ្នោតនេះ ។ ជាទូទៅក្នុងខេត្តបាត់ដំបងចាប់តាំងពីបោះឆ្នោតលើកទី ១ រហូតមកដល់បោះឆ្នោតព្រឹទ្ធសភានេះ ដែលរៀបចំឡើងដោយ គជប គឺយើងមានបញ្ហាមួយចំនួនដែលពាក់ព័ន្ធចំពោះការបោះឆ្នោត ហើយបានលេចចេញ ពីដំណាក់កាលនៃការឃោសនាបោះឆ្នោត មានលេចចេញច្រើនដែលយើងបានដោះស្រាយជាបន្តបន្ទាប់ ។

**ទី៣.** គឺជាដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលសំខាន់បំផុតដំណាក់កាលនៃការរាប់សន្លឹកឆ្នោតបានលេចចេញជាបញ្ហា២ ទី១ គេចង់ឱ្យរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត ដើម្បីបង្ហាញពីតម្លាភាព ប៉ុន្តែមតិខ្លះទៀតលើកឡើងថាការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យ គឺធ្វើឱ្យមូលដ្ឋានរបស់ប្រជាពលរដ្ឋដែលបោះឆ្នោតនៅកន្លែងនោះមានការភ័យខ្លាច ដោយសារថាដឹងលទ្ធផលនៅក្នុងការិយាល័យនោះថាយ៉ាងម៉េច គាំទ្រនរណា ។ មតិខ្លះទៀតគាត់ថាឱ្យបញ្ចូលយកមករាប់នៅកន្លែងឃុំវិញ គឺនៅ CEC មតិពីរនេះជាមតិត្រូវទាំងអស់គ្នា ប៉ុន្តែការបោះឆ្នោតក្រុមប្រឹក្សាឃុំដែលយើងត្រៀមធ្វើនៅឆ្នាំ ២០០៧ នេះ យើងមិនដឹងជានីតិវិធីរបស់ គជប យ៉ាងម៉េចទេ តែយើងសង្ឃឹមថានឹងធ្វើដូចពីមុនមកអញ្ចឹង គឺរាប់នៅការិយាល័យបោះឆ្នោត ហើយបានដឹកលទ្ធផលមកឃុំវិញ ។

ជារួមលោកសូមបញ្ជាក់ដោយខ្លីៗតែប៉ុណ្ណឹង និងធ្វើការសន្និដ្ឋានថាការបោះឆ្នោតនីមួយៗអាចទទួលបានជោគជ័យទៅបានលុះត្រាតែភាគីអ្នកចូលរួមទាំងអស់មានឆន្ទៈនយោបាយ ចូលរួមដោយស្មោះស ។ ប៉ុន្តែបើសិនជាភាគីខ្លះចូលរួមដោយមិនស្មោះត្រង់នាំឱ្យការបោះឆ្នោតមិនអាចទទួលបានលទ្ធផលល្អទេ។ ដូចជាបញ្ហាបណ្តឹងអញ្ចឹង បណ្តឹងមួយស្របត្រឹមត្រូវតាមច្បាប់យើងអាចដោះស្រាយបានបណ្តឹងមួយទៀតដែលពិបាកបំផុតគឺបណ្តឹងនយោបាយ គឺមិនដឹងថាភាគីពាក់ព័ន្ធចង់បានរឿងអីទេ ចេះតែដោះស្រាយទៅ ។

លោក **សោ ចាន់ដេត** ក្រុមប្រឹក្សាគណបក្សសម រង្ស៊ី ចូលរួមកត់សម្គាល់លើបញ្ហា៣ នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតកន្លងមក:

**ទី១** ឃើញថាយន្តការនៃការរៀបចំរបស់ គជប បើយើងពិនិត្យជាទូទៅឃើញថាមានលក្ខណៈល្អប្រសើរណាស់ ប៉ុន្តែដល់ពេលមកអនុវត្តនៅតែមិនទាន់បង្ហាញអំពីឆន្ទៈនៃការធ្វើឱ្យប្រជាពលរដ្ឋខ្មែរចូលរួមបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ។ លោកបានបន្តថា តាមរយៈការលើកឡើងរបស់ លោក **ឱក សេរី សោភ័ក្តិ** គឺត្រឹមត្រូវប្រជាពលរដ្ឋនៅប្រទេសគេការចុះឈ្មោះបោះឆ្នោត គេស្ទើរតែជាដង្ហើមចេញចូលរបស់មនុស្សទៅហើយ ជាសិទ្ធិរបស់ពលរដ្ឋម្នាក់ៗ អញ្ចឹងការរៀបចំបញ្ជីចុះឈ្មោះបោះឆ្នោតការធ្វើបញ្ជីបច្ចុប្បន្នភាពអ្នកបោះឆ្នោត គឺ គជប បានធ្វើប្រតិភូកម្មអំណាចឱ្យទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ជាពិសេសស្មៀន ជាអ្នកទទួលខុសត្រូវ អញ្ចឹងយើងមិនគួរកំណត់ថា ឱ្យគាត់ធ្វើតែរយៈពេលខែតុលាមួយខែទេ គួរណាស់តែឱ្យគាត់ធ្វើទូទៅ វៀនលិទ្ធិប្រជាធិបតេយ្យពេញមួយឆ្នាំ លើកលែងខែតុលានេះ ទុកជាខែបិទបញ្ជីទៅ បិទបញ្ជី ដើម្បីឱ្យគាត់ធ្វើសេចក្តីរាយការណ៍ឡើងទៅ គជប ពីព្រោះយើងដឹងហើយប្រជាពលរដ្ឋមិនថាស្រុកខ្មែរ ឬស្រុកណា គាត់ចេញចូលចំណាកភូមិ ឃុំ ស្រុក របស់គាត់ មិនពិតប្រាកដទេ ពិសេស ស្រុកខ្មែរ គឺភាពក្រីក្រ ដោយសារការអត់ការងារធ្វើ ធ្វើឱ្យលោកចេញចូលធ្វើចំណាកស្រុកញឹកញាប់ ហើយមិនពិតប្រាកដ ។ អញ្ចឹងបើ កាលណាយើងកំណត់យកតែខែតុលាមួយសម្រាប់ចុះឈ្មោះ ធ្វើឱ្យប្រជាពលរដ្ឋភាគច្រើន ពិសេសអ្នកក្រនៅជនបទដាច់ស្រយាល ដែលគាត់ទាមទាររករបរចិញ្ចឹមជីវិតនៅក្រៅស្រុក ឧទហរណ៍ចំខែតុលាគាត់មិនបានមក គឺគាត់បាត់សិទ្ធិហើយ បើសិនយើងបើកទូលាយឱ្យគាត់ចុះឈ្មោះជារៀងរាល់ខែ គឺគាត់មានសិទ្ធិបានច្រើន យើងធានានូវការទទួលបាននូវសិទ្ធិពលរដ្ឋក្នុងការជ្រើសរើសតំណាងរបស់ខ្លួនបានច្រើន។ ប៉ុន្តែកាលណាយើងកំណត់ដូចពេលបច្ចុប្បន្ននេះបញ្ហានៅតែស្មុគ្រស្មាញដដែល ។

អំពីឯកសារ ដែលចុះទៅបំពេញឈ្មោះ ចុះឈ្មោះបោះឆ្នោត នៅតែមានបញ្ហាស្មុគ្រស្មាញ ដែលគាត់មានសិទ្ធិអាចទៅចុះឈ្មោះបោះឆ្នោតបាន គឺទាមទារឱ្យមានឯកសារច្រើន គឺការបញ្ជាក់ពីមេភូមិ និងអាជ្ញាធរដែនដី។ ជារឿងត្រឹមត្រូវហើយដែលត្រូវបញ្ជាក់ពី មេភូមិ និងអាជ្ញាធរដែនដី ប៉ុន្តែនៅស្រុកយើងអាជ្ញាធរដែនដីមិនទាន់ឯករាជ្យ នៅតែមានការរើសអើង។ ថ្មីៗនេះដែរយើងកំពុងតែធ្វើការ ដែលជាយន្តការមួយល្អណាស់ គឺការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោត ថ្មីនេះលោកដើរគ្រប់ឃុំទាំងអស់គ្រាន់តែចាប់ផ្តើមធ្វើ កិច្ចការនេះ គឺនៅតែមានការរើសអើងក្នុងការចែកប័ណ្ណ ដោយតំបន់ដែលបានទទួលព័តិមានច្រើនគឺនៅក្នុងទីរួមខេត្ត ឬជាយក្រុង ប៉ុន្តែ នៅតំបន់ដាច់ស្រយាល ដែលប្រជាពលរដ្ឋទទួលបានព័តិមានតិច ដែលសង្គមស៊ីវិល គណបក្សនយោបាយពិបាកនិងទៅដល់គឺស្ងាត់មិន ដឹងអីទាំងអស់ សូម្បីមន្ត្រីបុគ្គលិកនៅតុលាការ មិនទាន់ដឹងថាប័ណ្ណព័តិមានហ្នឹងយ៉ាងម៉េច ហើយមិនទាន់បានទទួលផងអញ្ចឹងយន្ត ការរៀបចំល្អហើយ តែឆន្ទៈមិនទាន់ល្អ ។ ដូចនេះប្រធានលេខាធិការដ្ឋានខេត្តដែលបានមានប្រសាសន៍ត្រឹមត្រូវណាស់ដែលថាសូមឱ្យ ភាគីចូលរួមទាំងសងខាងមានភាពស្មោះសទ្បេងត្រង់និងគ្នា ។

**ទី២** រឿងការឃោសនាបោះឆ្នោតកន្លងមកឃើញថា ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនៅមិនទាន់ស្មើភាព គណបក្សកាន់អំណាច នៅតែមានឱកាសច្រើនក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។ ជាសំនូមពរ គជប គួរតែរៀបយន្តការឡើងវិញជម្រុញឱ្យមានប្រព័ន្ធផ្សព្វផ្សាយឱ្យស្មើភាពគ្នារវាងគណបក្សនយោបាយ ។ មួយវិញទៀតគឺការដោះស្រាយវិវាទ តាមនីតិវិធីរបស់ គជប ល្អទាំងអស់ ប៉ុន្តែជាក់ស្តែងនៅមានកម្រិត ។ ឧទាហរណ៍ ឆ្នាំ២០០៣ មានទំនាស់មួយគណបក្សសម រង្ស៊ី បានប្តឹង តាមនីតិវិធីបើចង់យកកន្លែងណាមួយធ្វើវេទិការ គឺត្រូវសុំ PEC មុនសិន មួយសប្តាហ៍ ឬយ៉ាងតិចក៏៣ថ្ងៃដែរ គណបក្ស សមរស្ស៊ី បានសុំមុខវត្តកណ្តាលស្របនិងដងស្ទឹងសង្កែរ តាមនីតិវិធីបើគណបក្សណាគេអនុញ្ញាតឱ្យមុន គណបក្សមកក្រោយ មិនអាចមករំខានបានទេ ដល់ពេលអនុញ្ញាតឱ្យហើយគណបក្សសម រង្ស៊ីបានទៅរៀបចំធ្វើឆាក ពេលនោះគណបក្សប្រជាជនបានយកប៉ាដាមកចងជុំវិញឆាក នេះជាការល្មើសច្បាប់ ខុសនិងនីតិវិធីទាំងស្រុង ពេលនោះគណបក្សបាន ធ្វើពាក្យប្តឹងទៅតាមនីតិវិធី តែ PEC នៅមិនទាន់ប្រើនៅឆន្ទៈ និង

សិទ្ធិរបស់ខ្លួនដដែល គឺបណ្តឹងបានត្រឹមតែសម្របសម្រួល ។ ដូច្នេះសូមឱ្យ PEC គជប រៀបចំនីតិវិធីដោះស្រាយវិវាទឱ្យបានល្អ ទី១ ឱ្យមានការអង្កេត និងសវនាការឱ្យបានល្អត្រឹមត្រូវ ហើយ PEC នីមួយៗ ឱ្យហ៊ានប្រើនូវឆន្ទះ និងសិទ្ធិដែលច្បាប់ប្រគល់ឱ្យ ។

**ទី៣** ពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត យើងឃើញហើយការរៀបចំឱ្យមានភ្នាក់ងារគណបក្សនយោបាយចូលទៅជា រឿងត្រឹមត្រូវ ប៉ុន្តែឱ្យតែអ្នកពេញសិទ្ធិចូលរួមម្នាក់ ហើយមើលទៅការិយាល័យធ្វើការមានបុគ្គលិកច្រើននាក់ មានអ្នកឱ្យចាំជ្រលក់ទឹកខ្មៅ ផ្ទៀងគល់បញ្ជី បើយើងយកតែម្នាក់មើលម៉េចទាន់ទេ មនុស្សម្នាក់ធ្វើការ២-៣ ក្នុងពេលតែមួយ ។ អញ្ចឹងសូមឱ្យនីតិវិធី អនុញ្ញាតអ្នកសង្កេតការណ៍ទាំងសង្គមស៊ីវិល ទាំងតំណាងគណបក្សនយោបាយបានចូល ទើបអាចកាត់បន្ថយនូវទំនាស់ក្រោយការបោះឆ្នោតបាន ។

លោកស្រី **លឹម ប៊ុនធឿន** ជំទប់ទី១ ឃុំតាម៉ឺន គណបក្ស ហ៊្វុន ស៊ិនប៉ិច បានចូលរួមមតិ និងមានការឯកភាព លើការរៀបចំរបស់ គជប ក្នុងការសាកល្បងចែកប័ណ្ណព័ត៌មាន ក៏ប៉ុន្តែសូមកុំកំណត់តែមួយខែ ព្រោះលោកស្រីបានចុះត្រួតពិនិត្យតាមដាន គឺការចែកប័ណ្ណមិនទាន់បានទូលំទូលាយទេ មិនទាន់ជាប្រជាធិបតេយ្យទេ ព្រោះយើងមិនបានផ្សព្វផ្សាយជូនប្រជាពលរដ្ឋ ហើយភាគច្រើនពួកគាត់មិនដឹងទេថាគេធ្វើអីខ្លះ ហើយមានផ្តិតមេដៃទៀត ។ លោកស្រីថាគេចុះទៅស្រង់អត្តសញ្ញាណប័ណ្ណ ដើម្បីត្រួតពិនិត្យឱ្យចំឈ្មោះដើម្បីទៅបោះឆ្នោត អញ្ចឹងគាត់មិនបានដឹងនាំឱ្យគាត់មិនបាននៅផ្ទះ គាត់ត្រូវទៅធ្វើការងារបង្កបង្កើនផលរបស់គាត់ ។ លោកស្រី សូមសំណូមពរឱ្យផ្សព្វផ្សាយឱ្យបានទូលំទូលាយ ថាថ្ងៃនេះគណកម្មាការថ្នាក់ឃុំបានចុះមកត្រួតពិនិត្យអត្តសញ្ញាណប័ណ្ណ ដើម្បីឱ្យបង ប្អូនផ្ទៀងផ្ទាត់នៅប័ណ្ណបោះឆ្នោត ។

លោក **ឱក សេរី សោភក្តិ** បានជម្រាបអង្គប្រជុំថានៅខេត្តពីរទៀតមានបញ្ហាដូចគ្នា ដោយសារមេភូមិគាត់យកចែកតែគាត់មិនបានពន្យល់ប្រជាពលរដ្ឋ គាត់ចេះតែបង្ខំឱ្យផ្តិតមេដៃ ដល់ពេលប្រជាពលរដ្ឋមិនយល់ មិនព្រមផ្តិតមេដៃនាំឱ្យមិនបានទទួលប័ណ្ណ ។ បើសិនជាលោកមេឃុំគាត់ពន្យល់ថានីតិវិធីដើម្បីទទួលបាន និងមានការទទួលខុសត្រូវ គោងផ្តិតមេដៃថាប័ណ្ណបានប្រគល់ដល់អ្នកបោះឆ្នោត ម្នាក់នេះហើយ ប៉ុន្តែបើមិនពន្យល់ រឿងនេះទៅជាការបង្ខំឱ្យចូលគណបក្ស ព្រោះមានការផ្តិតមេដៃ ។ កន្លែងណាដែល យើងដោះស្រាយមិនបាន កន្លែងណាដែលទាក់ទងទៅនិងនីតិវិធី ព្រោះលោក វ៉ន ពន ធ្វើតាមនីតិវិធីដែល NEC បានដាក់មក ប៉ុន្តែលោកយល់ថាប័ណ្ណព័ត៌មាននៅតែជាប័ណ្ណ យើងបញ្ចប់ដើម្បីវាយតម្លៃមួយខែហ្នឹង តែយើងចែកតទៅទៀតទៅ ធ្វើយ៉ាងម៉េចឱ្យបាន ដល់ដៃអ្នកបោះឆ្នោតមុនថ្ងៃបោះឆ្នោត ។ លោកនឹងនាំពាក្យនេះទៅប្រាប់ខាង NEC ព្រោះយើងនឹងមានការប្រជុំនៅថ្នាក់ជាតិ ពេលត្រឡប់ទៅវិញអ្វីដែលជាសំណូមពរទាំងប៉ុន្មាននឹងយកទៅជម្រាបឯកឧត្តម ទេព នីថា ដែលមកប្រជុំរាល់ពេល ហើយយើងជួយ NEC កំណែទំរង់នីតិវិធីបានច្រើនណាស់ ហើយនៅថ្ងៃច័ន្ទនេះ គឺប្រជុំពិនិត្យមើលលើសេចក្តីព្រាងដែលបានប្រកាសពីម្សិលម៉ិញជាសាធារណៈ តាមរយៈសន្និសីទកាសែត ។

លោក **វ៉ន ពន** សូមបញ្ជាក់ត្រង់ចំណុចដែលថាអាជ្ញាធរឃុំមិនបានទៅផ្សព្វផ្សាយដើម្បីចែកប័ណ្ណព័ត៌មានជូនដល់អ្នកបោះឆ្នោត ។ នៅក្នុងនេះនីតិវិធី យើងធ្វើអញ្ចឹងប័ណ្ណនេះយកទៅជូនគាត់ផ្ទាល់តែម្តង ប្រសិនបើសាម៉ីខ្លួនទទួលដោយផ្ទាល់អ្នកដែលផ្តល់ប័ណ្ណនិងគូសគ្រីសត្រង់ប្រអប់មួយពីមុខឈ្មោះអ្នកបោះឆ្នោត អត់មានឱ្យផ្តិតមេដៃទេ ប៉ុន្តែបើឈ្មោះហ្នឹងគាត់អវត្តមានមិនបាននៅ

ហើយតំណាងរបស់គាត់ ដូចជាបង ប្អូន ប្រពន្ធ កូន អាចយកជំនួសបាន ប៉ុន្តែអ្នកដែលយកជំនួសត្រូវចុះហត្ថលេខានៅគល់បញ្ជី ឬផ្តិតមេដៃ ។

ចំណែកការផ្សព្វផ្សាយនីតិវិធីមិនមានទេ គឺនេះជាព័ត៌មានយកទៅជូនគាត់ផ្ទាល់តែម្តង ។ ដោយពេលដែលយើងធ្វើនេះមិនបានជួបគាត់ច្រើន ដោយសារគាត់រវល់ទៅរកស៊ីកន្លែងឆ្ងាយៗ អញ្ចឹងអ្នកតំណាងដែលទទួលជំនួសតាមរបាយការណ៍ឃើញថាស្មើជាមួយអ្នកទទួលផ្ទាល់ ។

បញ្ហារបស់លោក សោ ចាន់ដេត ដែលបានលើកឡើងពីបញ្ហានៃការចុះឈ្មោះបោះឆ្នោត គឺមានរយៈពេលខ្លីពេកតែមួយខែនេះ លោកដាក់ពេលមួយខែវែងពេកហើយ តាមច្បាប់តែ ២០ ថ្ងៃទេ ចាប់ពីថ្ងៃទី ១ ខែតុលា ដល់ថ្ងៃទី ២០ ខែតុលា រៀងរាល់ឆ្នាំ បើសិនជាឆ្នាំ ណាដែលចំភ្ជុំយើងខាតអស់ ៣ថ្ងៃ ដូចឆ្នាំទៅមិញយើងធ្វើបានតែ ១៧ ថ្ងៃ ប៉ុន្តែនៅក្នុងនោះយើងបានឱ្យប្រជាពលរដ្ឋនៅភូមិនីមួយៗធ្វើការចុះឈ្មោះត្រៀម អ្នកដែលមិនទាន់បានចុះឈ្មោះ និងអ្នកដែលគ្រប់អាយុទៅដល់ចុះឈ្មោះបោះឆ្នោត ។ កាលលោក ចាន់ដេត មានប្រសាសន៍ថាការចុះឈ្មោះមានភាពស្មុគ្រស្មាញ ដែលមានឯកសារបួន ហើយឯកសារនេះដែលសំខាន់ជាងគេគឺឯកសា បញ្ជាក់សញ្ជាតិ អញ្ចឹងអ្នកដែលគ្រប់អាយុ ដែលមកត្រៀមចុះឈ្មោះ ការត្រៀមនេះឃុំនីមួយៗត្រូវធ្វើតាំងពីថ្ងៃទី ១ ខែមករា រៀងរាល់ឆ្នាំរហូតដល់ថ្ងៃទី ១៨ ត្រៀម ។ ដើម្បីចង់ដឹងថាតើអ្នកដែលចុះឈ្មោះមានឯកសារអ្វីខ្លះ ឧទាហរណ៍ឯកសារបួនដែលត្រូវចុះឈ្មោះ ហើយគាត់មានតែបីស្មៀនឃុំគាត់គ្រីសបីនេះដែលមានឯកសារហើយ និងបញ្ជាក់ប្រាប់គាត់វិញថាត្រូវមកអញ្ជើញមកចុះឈ្មោះជាផ្លូវការពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី ២០ តុលា ដោយយកឯកសារទាំងបួនមក ហើយឯកសារដែលមានបីក៏យកមកដែរ និងឯកសារមួយទៀតដែលមិនទាន់មានត្រូវបំពេញឱ្យហើយ ឧទាហរណ៍ថាបញ្ជាក់ទីលំនៅត្រូវបំពេញ ១០១៩ ដើម្បីឱ្យគ្រប់ឯកសារទាំងបួនទើបអាចចុះឈ្មោះបាន ។

បញ្ហាការរើសអើងលោកកំពុងតែធ្វើការស្រាវជ្រាវមើល ប៉ុន្តែការចែកប័ណ្ណនេះ មានធ្វើប្រតិទិនច្បាស់លាស់ ក្នុងឃុំនីមួយៗ ។ ឧទាហរណ៍ ថ្ងៃទី១ ដល់ថ្ងៃទី៣ ខែសីហា ត្រូវចុះទៅភូមិណាមុន ហើយបើចុះទៅភូមិណាមេភូមិអាចអញ្ជើញ ប្រជាពលរដ្ឋមកក្នុងមួយពេលដើម្បីមកចែក ឬមួយចែកមិនទាន់អស់ទេ ក្រុមប្រឹក្សាឃុំ និងលោកមេភូមិដើរទៅតាមផ្ទះ បានចប់ភូមិ មួយនេះហើយទៅភូមិមួយទៀត បន្តបន្ទាប់គ្នារហូតដល់ថ្ងៃ ៣១ ខែសីហា ។ នេះខ្ញុំយល់ថាប្រហែលជាភូមិនោះមិនទាន់ទៅដល់ទេ ហើយក៏សូមបញ្ជាក់ដែរថា ប័ណ្ណព័ត៌មាននេះមិនមែនចែកតែមួយខែនេះចប់ទេ បើមួយខែចែកមិនអស់ត្រូវរក្សានៅឃុំដដែលឱ្យលោក មេឃុំបង្គាប់ឱ្យស្មៀនឃុំចែក នៅពេលណាដែលឃើញប្រជាពលរដ្ឋដែលគាត់មិនទាន់បានទទួល ចែកបន្តទៅគាត់ទៀត រហូតដល់ថ្ងៃចុះឈ្មោះគឺថ្ងៃទី១ ខែតុលា ដើម្បីឱ្យគាត់ ពិនិត្យមើលថាតើឈ្មោះ និងទិន្នន័យផ្សេងៗត្រឹមត្រូវឬទេ ។

ចំពោះបញ្ហាដែលលោកថា មានមន្ត្រីខ្លះដែលមិនទាន់ដឹង មិនបានទទួលប័ណ្ណ ប្រហែលជាសាម៉ីខ្លួនមិនបាននៅផ្ទះ ឬផ្ទះបិទទ្វារ ក្រុមចែកគេទៅមិនជួប ។ តាមរយៈវេទិកានេះសូមខាងគ្រប់គណបក្សនយោបាយជួយផ្សព្វផ្សាយផង បើពុំទាន់បានទទួលប័ណ្ណទេសូមឱ្យទៅសាលាឃុំដើម្បីសុំចុងសន្លឹកយកមកពិនិត្យមើលថាត្រូវ ឬខុស ហើយសំខាន់គាត់អាចនៅពេលបោះឆ្នោតនៅក្នុងនោះមានឈ្មោះ លេខ រៀង ថ្ងៃខែឆ្នាំកំណើត ភេទ នៅក្នុងបញ្ជីរបស់គាត់ ។ លោកចាប់អារម្មណ៍ជាងគេរឿងភេទ ជួនកាលគាត់ស្រី ប៉ុន្តែដាក់ភេទគាត់ប្រុស នេះនៅពេលទៅបោះឆ្នោតមិនដឹងយកឯកសារអីទៅបញ្ជាក់ទេ ។ អញ្ចឹងសូមឱ្យអស់លោកជួយជម្រុញយ៉ាងម៉េចឱ្យប្រជាពលរដ្ឋ ទទួលប័ណ្ណទាំងអស់គ្នា អ្នកដែលមានឈ្មោះបោះឆ្នោត ដើម្បីជៀសវាងបញ្ហាកំហុសឆ្គងទាំងឡាយ ។

លោក **ឯម សារិន** ជំទប់ទី២ ឃុំរតនៈ គណបក្ស សមរង្ស៊ី សំណូមពរសុំឱ្យ គជប ប្រគល់ទៅឱ្យមេឃុំខ្លះរឿងចុះចែកប័ណ្ណព័ត៌មាន ព្រោះសព្វថ្ងៃប័ណ្ណព័ត៌មានដែលចែក ទោះកំណត់ថាមួយខែក្នុងខែសីហាឱ្យចប់ នៅភូមិលោកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ៨ ពាន់នាក់ជាង ហើយកន្លះខែទៅដែលបានចុះទៅចែកប័ណ្ណព័ត៌មានដល់ប្រជារាស្ត្រទើបបានជាង ១ពាន់ គិតទៅប្រហែលជាង១០ ភាគរយ ។

បញ្ហាមួយទៀត គឺចុះឈ្មោះបោះឆ្នោត ដូចប្រសាសន៍របស់តំណាងគណបក្ស សមរង្ស៊ីថា ស្មុគ្រស្មាញណាស់សម្រាប់ខ្មែរយើងចុះឈ្មោះបោះឆ្នោត តែបើសម្រាប់យួនងាយស្រួលជាទីបំផុត ។ ឧទាហរណ៍ថាកូនសិស្សលោកគាត់នៅវត្តបើមកចុះឈ្មោះ នៅបញ្ជាក់អាជ្ញាធរ ហើយអាជ្ញាធររុញទៅវិញឱ្យបញ្ជាក់ចៅអធិការឱ្យចុះហត្ថលេខា រុញទៅ រុញមកមិនបានចុះ ។ បើចំពោះយួនស្រួលពេលមកគេចុះឱ្យគេមានអ្នកធានា បើចំពោះខ្មែរមានអ្នកធានា ធ្វើអេសអុញថារូបថតមិនច្បាស់ ទៅរក២សន្លឹកទៀត យកពាគុណ៤ នេះហើយដែលពិបាកដល់ខ្មែរ ដែលចង់បោះឆ្នោតរើសតំណាងអ្នកដែលយើងពេញចិត្ត ។

រឿងប័ណ្ណបោះឆ្នោត ពីឆ្នាំ ១៩៩៣ ១៩៩៨ ២០០១ ឈប់ឱ្យបោះហើយ នៅអាណត្តិក្រោយយកអត្តសញ្ញាណប័ណ្ណបើតាមទស្សនៈលោកពិបាកណាស់សំរាប់ប្រជាពលរដ្ឋខ្មែរ ព្រោះបើគាត់យកអត្តសញ្ញាណប័ណ្ណទៅបោះ ពេលខ្លះគាត់មិនដឹងការិយាល័យណាផង បើគាត់កាន់ប័ណ្ណបោះឆ្នោតចាស់គាត់ដឹងថាគាត់បោះឆ្នោតនៅវត្តគោកថ្កុង ហើយនៅទីនោះមាន២ការិយាល័យ គឺ០២១៤ និង០២១៥ ខ្លះគាត់មិនចេះហើយចាស់ផងទៅដល់គាត់មិនដឹងបោះកន្លែងណាទេ បើសិនគាត់យកប័ណ្ណបោះឆ្នោតទៅគាត់អាចឱ្យគេជួយមើល ។ ម្យ៉ាងទៀត ដែលថាឱ្យអ្នកដែលមានប័ណ្ណបោះឆ្នោតឱ្យទៅធ្វើថ្មី គឺមានការពិបាកណាស់សំរាប់គាត់ឱ្យយករូបថត២សន្លឹក ហើយគាត់ ក្រណាស់មានលុយឯណា មួយទៀតឱ្យគាត់ទៅធ្វើម្តងទៀតពិបាកណាស់សំរាប់គាត់ ។ លោកសូមស្នើថា NEC គួរតែអនុញ្ញាតឱ្យប័ណ្ណបោះឆ្នោត២០០១ មានប្រសិទ្ធិភាពវិញ ដូចជាអត្តសញ្ញាណប័ណ្ណ ប័ណ្ណប៉ូលីស ប័ណ្ណមន្ត្រីរាជការ ។

លោក **ឱក សេរី សោភក្តិ៍** នៅក្នុងយន្តការ ឧប់សែល នេះ ចំពោះចំណុចទី៣ ដោយសារអត្តសញ្ញាណប័ណ្ណមិនអាចប្រើការបាន ចំពោះលេខរៀង និងទីកន្លែងបោះឆ្នោត ដូច្នេះហើយបានជា គជប ចេញប័ណ្ណព័ត៌មានដែលមានបញ្ជាក់ឈ្មោះ ទីកន្លែងបោះឆ្នោត ប៉ុន្តែ អត្តសញ្ញាណប័ណ្ណជាតិ ដាច់ខាត គឺសំខាន់ណាស់ ព្រោះមិនមែនប្រើការតែរឿងបោះឆ្នោតទេ ធ្វើអីក៏ដោយតែកើតឡើងជាកូនខ្មែរត្រូវតែមានអត្តសញ្ញាណប័ណ្ណ ដល់អាយុ ១៨ ឆ្នាំ ត្រូវតែបានទទួល។ ដូច្នេះរឿងពីរនេះមិនអាចទៅបានទេ ប៉ុន្តែបើយើងមានអត្តសញ្ញាណប័ណ្ណជាតិផ្គួបជាមួយប័ណ្ណព័ត៌មានគ្រប់តែម្តង ដូច្នេះលោកថាលក្ខណៈនេះមិនចោទជាបញ្ហាទេបើគិតជានីតិវិធី ។ ចំណែករឿងអាណិកជនវៀតណាម បញ្ហានេះអាចក្លាយទៅជាទំនាស់ អាចជាជម្លោះដោយសារអាចត្រូវបំប៉ោងជារឿងនយោបាយ អញ្ចឹងហើយបានជាយន្តការ ឧប់សែល ប្រយ័ត្នណាស់ ដូច្នេះបើសិនជាវាគ្និនណាលើក យើងធ្វើការជាមួយ គជប គណបក្សនយោបាយ ក្រសួងមហាផ្ទៃ នៅថ្នាក់ជាតិឱ្យតែលើកយើងសូមតែបញ្ជាក់ឈ្មោះទីកន្លែង អាជ្ញាធរនៅកន្លែងនោះឈ្មោះអី ហើយគ្រួសារវៀតណាមនោះឈ្មោះអី យើងនឹងចុះទៅស៊ើបអង្កេត ព្រោះបើសិនជាចោទមិនច្បាស់ពិបាកយកជាបានការណាស់ រឿងនេះជារឿងម៉ត់ចត់ខ្លាំងមែនទែនអាចធ្វើឱ្យមានជម្លោះ អាចឈានដល់ជម្លោះពូជសាសន៍ ពេលនោះអ្នកណាក៏មិនអាចត្រួតត្រាបានដែរ ។ ដូច្នេះការមានប្រសាសន៍ គឺមានខ្លឹមសារល្អ ហើយម៉ត់ចត់ បើសិនជាមានទីកន្លែងច្បាស់លាស់លោកសូម ដើម្បីឱ្យខាងក្រសួងមានសមត្ថកិច្ច និងខាងសង្គមស៊ីវិលឯទៀត ដែលនៅកន្លែងនោះចុះទៅមើលតែម្តងថា តើរឿងនោះពិតប្រាកដមែន ឬមិនមែន បើមានកន្លែងណាយើងដេញឱ្យដល់កន្លែងនោះទើប បានយើងច្បិចរឿងនេះកុំឱ្យរាលដាលបាន ។ ឧទាហរណ៍ ដូចនៅថ្នាក់ជាតិ ខាងគណបក្សប្រជាធិបតេយ្យខ្មែរលើកថាគាត់យកអ្នកកាត់ ដេរ ២០ នាក់មក ប៉ុន្តែដើម្បីយកមកធ្វើការរោងចក្របានទាល់តែមានអត្តសញ្ញាណប័ណ្ណ ដល់គាត់ទៅធ្វើប៉ុស្តិ៍ប៉ូលីសទារ

លុយ ហើយគាត់ឱ្យឈ្មោះប្រធានប៉ុស្តិ៍ប៉ូលីសនោះ ភូមិ ឃុំនោះឈ្មោះអី ហើយលោកដែលជាសមាជិក ខប់សែល ពីរនាក់ចុះទៅស៊ើបអង្កេតមើលឃើញបញ្ហានេះភ្លាម គាត់កែខៃ ២០ នាក់នោះបានអត្តសញ្ញាណប័ណ្ណ ហើយមិនអស់លុយទៀត ។ រឿងធំទាល់តែយើងធ្វើការឱ្យម៉ត់ចត់ តែកាលណារឿងមួយហើយចោទផ្តេសផ្តាស់ ហើយបើប៉ូលីសម្នាក់ធ្វើខុស ហើយយើងចោទថាស្ថាប័ននោះធ្វើខុសមិនអាចទេ កន្លែងណាខុស កន្លែងនោះត្រូវទទួលខុសត្រូវ នេះយន្តការ ខប់សែល គឺមានបំណងធ្វើបែបនេះមិនបណ្តោយឱ្យកន្លែងណាដែលខុស ហើយចេះតែខុសតទៅទៀតទេ កន្លែងនេះហើយដែលយើងបានទទួលកិច្ចសហប្រតិបត្តិការពីខាងគណបក្សនយោបាយ អាជ្ញាធរមូលដ្ឋាន ស្ថាប័នជាតិទាំងអស់ ដើម្បីយើងចូលរួមធ្វើការទាំងអស់គ្នា នេះបានការហៅថាការតិទៀន ដើម្បីកសាងសង្គមជាតិរបស់យើង ។

លោក **អ៊ុត ធឿន** ជំទប់លេខ២ ឃុំជ្រៃ ស្រុកមោងឫស្សី គណបក្ស សម រង្ស៊ី សំណូមពរដល់ គជប

**ទី១** ការចែកប័ណ្ណព័ត៌មានដល់ប្រជាពលរដ្ឋ លោកសំណូមពរថា សូមឱ្យតំណាងគណបក្សនយោបាយទាំងបីដែលមានអាសនៈក្នុងសភាចុះជាមួយមេភូមិ និងក្រុមប្រឹក្សាឃុំ នេះជាចំណុចមួយដែលល្អហើយគ្មានការចោទប្រកាន់ ។

**ទី២** ការចុះឈ្មោះបោះឆ្នោតនៅខែ១០ វៀងរាល់ឆ្នាំ តាមការជាក់ស្តែងនៅក្នុងមូលដ្ឋានឃើញថាពេលដែលត្រូវចុះឈ្មោះបោះឆ្នោត គឺក្រុមប្រឹក្សាឃុំបានកោះហៅ លោកមេភូមិបានដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ តែការផ្សព្វផ្សាយនោះមិនបានជិតដល់ទូលំទូលាយ ។ ឧទាហរណ៍មេភូមិគាត់នៅពាក់ព័ន្ធនិន្នាការគណបក្សនយោបាយ គាត់ប្រាប់តែគ្នាគាត់ទេ ក្រៅពីគណបក្សគាត់មិនប្រាប់ទេ នេះជាចំណុចមួយដែលកើតមានជារៀងរាល់ថ្ងៃ ។ សំណូមពររបស់លោកសុំឱ្យ គជប ធ្វើម៉េចដូចជាដាក់មេក្រូផ្សព្វផ្សាយតាម មេភូមិផង តាមសាធារ ណៈផង ដើម្បីឱ្យគាត់បានជ្រាបគ្រប់ៗគ្នា ។

**ទី៣** ពាក់ព័ន្ធនិងអាជ្ញាធរប៉ូលីស ការធ្វើអត្តសញ្ញាណប័ណ្ណឱ្យប្រជាពលរដ្ឋដែលបានបាត់ និងគ្រប់អាយុ ឃើញថានៅស្រុកម៉ោង ឃុំជ្រៃបានយកលុយ យើងថាជួយប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ តើកាត់នៅកន្លែងណា? សូមសួរទៅស្ថាប័នពាក់ព័ន្ធ ។ លោកបានទៅចុះសួរ ដូចឃើញធ្វើនៅភូមិដូនទ្រី ឃុំជ្រៃ អ្នកដែលមានសៀវភៅគ្រួសារ ហើយខុសអាយុ ឬអ្នកមិនមានសៀវភៅគ្រួសារ អ្នកដែលមិនមានសំបុត្របញ្ជាក់កំណើតនោះ គាត់ឱ្យបញ្ជាក់ចេញពីប៉ុស្តិ៍មួយទៀត ហើយគាត់យក ១០០០ រៀល នេះចំណែកប៉ុស្តិ៍ ខាងលក់ក្រដាស ២០០០ រៀល អ្នកសរសេរ ៥០០រៀល អញ្ចឹងក្នុងម្នាក់ត្រូវចំណាយ ៣៥០០ រៀល ហើយបើគ្រួសារគាត់ ៥នាក់ចំពោះអ្នកខាងលើតិចតួចទេ តែចំពោះអ្នកអត់ ជាក់ស្តែងផ្ទះអ្នកផ្ទះមុខផ្ទះក្រោយ ហើយចេញតែប្រកាសតាមព័ត៌មានអត់យកលុយតាមការពិតយក ។

**ទី៤** ធ្វើការបោះឆ្នោតនៅក្នុងគណបក្ស ភូមិនេះពាក់ព័ន្ធនិងគណបក្សនយោបាយ ។ ឧទាហរណ៍ ដូចជាគណបក្សលោកកាន់លិទ្ធប្រជាធិបតេយ្យពិតប្រាកដ អញ្ចឹងក្នុងការដឹកនាំមិនថាថ្នាក់ភូមិ ឃុំទេ កើតឡើងពីការបោះឆ្នោតទាំងអស់ តែការបោះឆ្នោតនោះមន្ត្រីគណបក្សបានចុះទៅធ្វើការបោះឆ្នោតតាមភូមិនីមួយៗយើងឃើញថានៅភូមិស្រះគុយ ក្រោយពីបោះឆ្នោតគណបក្សហើយមានអាជ្ញាធរមេភូមិហៅគាត់មកគំរាមគំហែង សម្លុតថាបើអ្នកឯងចូលគណបក្ស សមរង្ស៊ីក៏ចូលចុះ ប៉ុន្តែថ្ងៃក្រោយបើពាក់ព័ន្ធរឿងរ៉ាវអ្វីមួយ គឺ ទៅពឹងសម រង្ស៊ីទៅ កុំទៅពឹងគេជាអាជ្ញាធរមេភូមិ ។

លោក**ស្រី ប៊ុត រឿត** ជំទប់ទី២ ឃុំភ្នំសំពៅ លោកស្រីបានទៅជួបផ្ទាល់អ្នកដែលចុះចែកប័ណ្ណព័ត៌មានមិនបានដើរតាមផ្ទះទេ គាត់អង្គុយនៅមួយកន្លែង ដល់ពេលអ្នកដែលមានវិវាទ ឬអន់ចិត្តនិងគ្នាមិនបានយកទៅផ្ទៀងទេ ។ ជាសំណូមពរសុំឱ្យអ្នកដែលចុះ

ចែកប័ណ្ណព័តិមានដើរតាមផ្ទះវិញ ។ មួយទៀតការចុះឈ្មោះបោះឆ្នោតអ្នកដែលមកពីខេត្តឆ្ងាយ គ្នាមិនទាន់បានយកតារាងចុះចូលទៅក្នុងកន្លែងប៉ូលិស តែគ្នាចង់បោះឆ្នោត មេភូមិមិនអនុញ្ញាតឱ្យគ្នាចុះឈ្មោះបោះឆ្នោតទេ ដល់អញ្ចឹងគាត់មករកលោកក៏ទៅសម្រួលដល់ ស្មៀន ហើយស្មៀនក៏បានជួយរកសាក្សី២នាក់ ឱ្យអាចបង្កលក្ខណៈបាន លោកទៅប្រាប់មេភូមិគាត់ថាមិនអាចចុះឈ្មោះបានទេព្រោះ យើងគ្មានឯកសារគ្រប់គ្រាន់ ។

ចំពោះការធ្វើអត្តសញ្ញាណប័ណ្ណសុំឱ្យធ្វើបន្ថែមទៀតព្រោះអ្នកខ្លះទៅរកស៊ីនៅស្រុកឆ្ងាយ មានការចំណាកស្រុក មកធ្វើមិនទាន់ទេ ហើយចុះធ្វើម្តងមិនបានផ្សព្វផ្សាយឱ្យបានជិតដល់ទេ មេភូមិគាត់មិនអាចទៅប្រាប់គ្រប់ផ្ទះបានទេ យើងគួរតែផ្សព្វផ្សាយបើចុះភូមិណាយើងផ្សាយតាមមេក្រូ ឬឱ្យអនុភូមិ សមាជិកភូមិ មេភូមិ ដើរប្រាប់បន្ត ដើម្បីឱ្យបានដឹងឮដល់ប្រជាពលរដ្ឋគ្រប់គ្នា ។

លោក **ឱក សេរី សោភក្តិ៍** សូមលើកឧទាហរណ៍មួយដែលបានជួបនៅប៉ៃលិន ថាតើវប្បធម៌នៃការជជែកពិភាក្សាគ្នាមានប្រយោជន៍ប៉ុណ្ណា ។ មានអ្នកតំណាងគណបក្សមួយគាត់លើកឡើងក្នុងអង្គប្រជុំ គិតថាការលើកឡើងរបស់គាត់ គឺរុញប្រធានស្នងការឱ្យ ទល់ច្រក គាត់លើកឡើងថាមានប្រជាពលរដ្ឋម្នាក់បាត់កាតហើយទៅធ្វើថ្មីហើយទារ ៥០ ០០០ រៀល តែច្បាប់អត់មានទេ ហើយនៅ ក្នុងអង្គប្រជុំស្តាប់ដោយយកចិត្តទុកដាក់ខ្លាំងមែនទែន ដល់ពេលអញ្ចឹងលោកផ្តល់សំដីទៅឱ្យលោកស្នងការ ហើយ លោកស្នងការគាត់ចាប់ផ្តើមឡើងគាត់និយាយថាមែន តែគាត់បញ្ជាក់មកវិញថាករណីនេះជាការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋម្នាក់នោះ។ កាលដែលម្នាក់នោះធ្វើ ឱ្យខូចប័ណ្ណ ហើយទិន្ន័យធ្វើនៅក្រុមហ៊ុនចិន នៅភ្នំពេញ ដើម្បីជិះឡានទៅយកទិន្ន័យចេញពីកុំព្យូទ័រ និងត្រូវត្រឡប់ទៅវិញត្រូវ ចំណាយលើស ៥០ ០០០ រៀល ទៀត នេះគ្រាន់តែចំណាយប័ណ្ណមួយអ្នកដែលធ្វើខូចជិតដល់ ១០០ ០០០ រៀលទៀត ។ បើមិនឱ្យយក ហើយថវិការជាតិអត់មាន ដើម្បីឱ្យប្រជាពលរដ្ឋមានប័ណ្ណឡើងវិញ ឱ្យគាត់ធ្វើយ៉ាងម៉េច គាត់ទទួលខុស គាត់ថាយកនេះខុសហើយ គាត់សួរអង្គប្រជុំថាឱ្យគាត់ធ្វើយ៉ាងម៉េចអង្គប្រជុំថាបើដឹងរឿងអញ្ចឹងមានអី មកពីមិនដឹងរឿងបានចោទ ។ នេះជាការមួយនៅពេលដែលមិនដឹងរឿងចោទគ្នាក្តៅគគុក ដល់ពេលដឹងហើយបកស្រាយសុំទោសរួចគ្នាតែម្តង ដូច្នេះរឿងបើថា បានប័ណ្ណហើយកុំធ្វើឱ្យខូចទៀត បើខូច ៥០ ០០០រៀលហើយ ។

លោកវីរៈសេនីយត្រី **សុខ តុលា** តំណាងឱ្យស្នងការដ្ឋាននគរបាលខេត្ត បានមានយោបល់លើកឡើងជុំវិញការធ្វើអត្តសញ្ញាញប័ណ្ណសញ្ជាតិខ្មែរ ស្របពេលការបោះឆ្នោតខិតជិតមកដល់ហើយ គឺការបោះឆ្នោតឃុំ-សង្កាត់ នឹងធ្វើនៅឆ្នាំ ២០០៧ និងការបោះឆ្នោតតំណាងរាស្ត្រនឹងធ្វើនៅឆ្នាំ ២០០៨ ខាងមុខ ។ ដូច្នេះជាគោលការណ៍រួមរបស់ គជប គឺកំណត់ឱ្យមានការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាមូលដ្ឋាន ក្នុងការផ្តល់ជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោត។ បញ្ហានេះត្រូវបានអគ្គស្នងការដ្ឋាននគរបាលជាតិកំណត់ផែនការមកខាងស្នងការដ្ឋាននគរបាលខេត្ត គឺចាត់ទុកបញ្ហានេះជាបញ្ហាគន្លឹះដែលត្រូវខិតខំធ្វើយ៉ាងណាអនុវត្តឱ្យបានសម្រេចក្នុងការផ្តល់នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនដល់ពលរដ្ឋខ្មែរទូទាំងខេត្តបាត់ដំបងទាំងមូល ឱ្យបានរួចស្រេចមុនការបោះឆ្នោតឈានមកដល់ ។ សរុបជាលទ្ធផលនៃការអនុវត្តផែនការមកទល់នឹងពេលនេះ តាមការបូកសរុបលទ្ធផលនៃការធ្វើគឺស្នងការដ្ឋាននគរបាលខេត្តធ្វើបានចំនួន ៨៥ ភាគរយហើយ ។ បានន័យថា អត្តសញ្ញាណប័ណ្ណដែលបានធ្វើជូនប្រជាពលរដ្ឋមកទល់ថ្ងៃនេះគឺបានចំនួន ៨៥ ភាគរយ លើ ១៣ ស្រុកទូទាំងខេត្ត ។ ជាមួយនេះដែរ ស្នងការដ្ឋាននគរបាលខេត្ត បានបែកចែកជូន ប្រជាពលរដ្ឋសរុបមកទល់ថ្ងៃនេះគឺបានចំនួន ៧០ ភាគរយហើយ នៅសល់ប្រហែល ១៥ ភាគរយនឹងផ្តល់ជូនជាបន្តបន្ទាប់ទៀត ។ ដោយឡែកចំនួនដែល

នៅសេសសល់បច្ចុប្បន្នកំលាំងជំនាញរបស់ស្នងការដ្ឋាននគរបាលខេត្ត និងអធិការដ្ឋាននគរបាលស្រុក ព្រមទាំងអាជ្ញាធរនៅមូលដ្ឋានបាននឹងកំពុងខិតខំសស្រាក់សស្រាំ ដើម្បីជម្រុញធ្វើយ៉ាងណាឱ្យបញ្ចប់ការងារនេះនៅមុនបំណាច់ឆ្នាំ ២០០៦ នេះ ។ បញ្ហាសំខាន់លំបាកដែរ ដែលយើងបានជួបប្រទះ គឺប្រជាពលរដ្ឋមួយចំនួនគាត់មានមុខរបរទៅឆ្ងាយ ជួនកាលគាត់ទៅច្រើនខែពេលដែលយើងមានផែនការចុះធ្វើអត្តសញ្ញាណប័ណ្ណ គាត់មិនទាន់មានលទ្ធភាពវិលត្រឡប់មកទាន់ពេល ដូច្នេះត្រូវបន្តរង់ចាំគាត់ ។ ជាចម្លើយចំពោះសំណួរបងស្រី ដែលបានលើកមកគឺ ការធ្វើអត្តសញ្ញាណប័ណ្ណនេះមិនបានផ្អាកទេ នៅតែបន្តធ្វើរហូតទាល់តែពលរដ្ឋដែលមានសិទ្ធិទទួលបានអត្តសញ្ញាណប័ណ្ណអាចទទួលបានគ្រប់ៗគ្នា ។ ស្របជាមួយគ្នានេះ ស្នងការដ្ឋាននគរបាលសូមឆ្លើយតប ចំពោះសំណួរបងប្រុសនៅស្រុកមោង ដែលបានលើកឡើងពីករណី កើតមានបញ្ហាការយកលុយកាក់ក្នុងការធ្វើអត្តសញ្ញាណប័ណ្ណ ជាគោលការណ៍របស់ក្រសួងក៏ដូចជាអគ្គ និងស្នងការដ្ឋាននគរបាលខេត្ត ពោលគឺគោលការណ៍របស់រាជរដ្ឋាភិបាល ការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋយើងមិនមាន តម្រូវឱ្យមានការបង់ប្រាក់ទេ គឺផ្តល់ជូនដោយមិនមានការបង់ប្រាក់ ។ ចំពោះករណីមានពាក់ព័ន្ធនេះ ស្នងការដ្ឋាននគរបាលខេត្តក៏មិនទាន់ដឹងច្បាស់ដែរ តែនឹងពាំនាំយកព័ត៌មាននេះរាយការណ៍ជូនលោកស្នងការបានជ្រាប ហើយនឹងចាត់វិធានការធ្វើការស្រាវជ្រាវស៊ើប អង្កេតជុំវិញករណីនេះ ។ ប្រសិនបើមានករណីនេះមែន ស្នងការដ្ឋាននគរបាលខេត្ត នឹងមានវិធានការម៉ឺងម៉ាត់ចំពោះបុគ្គលដែលបាន ប្រព្រឹត្តិខុសអំពីគោលការណ៍របស់ថ្នាក់លើ ។ ជាមួយគ្នានេះស្នងការដ្ឋាននគរបាលខេត្តសូមសំណូមពរ ប្រសិនបើមានករណីនេះអាចធ្វើ ជាពាក្យបណ្តឹងថានៅភូមិ ឃុំ និងកំលាំងនគរបាលឈ្មោះនេះ បានធ្វើសកម្មភាព ធ្វើអត្តសញ្ញាណប័ណ្ណដោយយកលុយកាក់ ហើយយើង អាចយកពាក្យបណ្តឹងនេះមកដាក់ជូននៅ នឹងស្នងការនគរបាលខេត្ត ដើម្បីអាចជាមូលដ្ឋានមួយឱ្យយើងងាយស្រួលក្នុងការចុះពិនិត្យ ស្រាវជ្រាវបន្ថែម ។

**លោក ឱក សេរីសោភ័ក្ត្រ** រឿងដែលធ្វើឱ្យមានប្រសិទ្ធិភាព គឺនៅពេលដែលមានករណីបែបនេះ ដូចជានៅភូមិ ដូនទ្រី យើងកុំចោល។ បងវីរៈសេនីយត្រីលោកមានប្រសាសន៍ដោយសន្យាថានឹងស៊ើបអង្កេត ។ ពីខប់សែលថ្នាក់ជាតិមក យើងនឹងជម្រាបសួរបងតាមពេលវេលា តាមរយៈស្នងការពីភ្នំពេញមកថាតើរឿងហ្នឹងបានដល់ណាហើយ ព្រោះរឿងជួនកាលយើងស៊ើបអង្កេតអត់បានជាក់ស្តែងទេ ប៉ុន្តែការខំប្រឹងប្រែងនឹងស៊ើបអង្កេតថាឥឡូវនេះមកដល់ណាហើយ ថាមកដល់ដំណាក់កាលហើយ នោះដែលយើងចង់បាន ។ ដូចជាការប្រឡងអញ្ចឹង ធ្លាក់ និងជាប់ជារឿងមួយ តែការខំប្រឹងរៀនយើងត្រូវតែទទួលស្គាល់ និងឱ្យតម្លៃ ។ ចង់បានតែប៉ុណ្ណឹងទេ កុំឱ្យ ថាលើកហើយបាត់ឈឹងៗ នោះទើបមានការលំបាក ។ អញ្ចឹងហើយបានជាមានករណីជាក់ស្តែងមក ខប់សែលនឹងតាមដានថាតើរឿងហ្នឹងដល់ណាហើយ ហើយនឹងជម្រាបជូនសាមីខ្លួនដែលបានលើករឿងហ្នឹងឡើង ។

លោក **ហេង មណីចិន្តា** នាយកអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ក្រោយពីបានស្តាប់អង្គប្រជុំកន្លះព្រឹកនេះទៅ គិតថាមានដំណោះស្រាយខ្លះ ដែលចង់ជូនជាមតិយោបល់ដើម្បីឱ្យដំណើរការយើងនេះបានទៅ ។ រឿងទាស់គ្នាមិនមានបញ្ហាទេ អ្វីដែលព្រួយគឺរឿងឈ្លោះគ្នា ព្រោះទាស់គ្នាកាន់តែច្រើនបានរូបភាពនៃមុំកាន់តែច្រើន ដូចជាបន្ទាត់ផ្តេកអញ្ចឹង បើមានបន្ទាត់មួយទៅទាស់ កើតបានមុំបួន ដូច្នេះរូបភាពនៃទំនាស់ធ្វើឱ្យវត្ថុមួយដែលមិនមាននណាបង្កើតក្លាយទៅវត្ថុបួន ហើយរូបរាងល្អ ។ តែពិបាកត្រង់រឿងឈ្លោះ ឈ្លោះមកពីពាក្យមួយដែរ គឺជួស បើមិនបានជួសធ្វើឱ្យកើតខ្ទុះគុំក្នុងហ្នឹង ដូច្នេះបើសិនជាឈ្លោះហើយមិនបានជួសរិតតែធ្ងន់ទៅទៀត ប៉ុន្តែបើឈ្លោះកើតឡើងហើយ បើយើងបង្ការបានត្រឹមទំនាស់មិនបញ្ហាអ្វីទេ ។ លោកឃើញទំនាស់ ៤ នៅក្នុងនេះ ទំនាស់ធំជាងគេគឺ

ទំនាស់នៃការផ្តល់ព័ត៌មានមិនបានគ្រប់គ្រាន់ ។ រឿងនេះបានលើកឡើងអំពីគណបក្ស លោក លោកស្រី ជំទប់ភាគច្រើន ហើយលោកខ្លួនឯងធ្លាប់មានការពិសោធន៏ក្នុងការងារឃើញអញ្ចឹងមែន ។ មានដំណោះស្រាយមួយដែលអាចជួយក្នុងរឿងហ្នឹងបាន លោកសូមផ្តល់ជូន ចំពោះបងខាងលេខាធិការដ្ឋាន គខប បងស្នងការ និងខាងខប់សែលដើម្បីនាំយកទៅជម្រាប គជប យើងគួរប្រើប្រាស់ធនធានដែលមាននៅហ្នឹងកន្លែង ។

ធនធានទី១. អង្គការសង្គមស៊ីវិល ដែលជាអង្គការក្រៅរាជរដ្ឋាភិបាលធ្វើការច្រើនណាស់នៅតាមមូលដ្ឋាន ប្រសិនជាខាង គខប អាចសុំសហការជាមួយ មិនមែនក្នុងនាមលោកអភិបាលខេត្តទេ គឺខាង គខប។ ឧទាហរណ៍ដូចជាមានបញ្ហាដែលត្រូវទៅផ្សព្វផ្សាយព័ត៌មានជាដើម សុំជួបអង្គការក្រៅរដ្ឋាភិបាលមួយថ្ងៃទៅ ថាឥឡូវខាង គខប មានគោលបំណងចង់ផ្សព្វផ្សាយអំពីការចែកប័ណ្ណដល់ប្រជាពលរដ្ឋអំពីការបោះឆ្នោត ហើយសូមឱ្យមានសហការពីអង្គការក្រៅរដ្ឋាភិបាល ជួយប្រាប់ដំណឹងដល់ប្រជាពលរដ្ឋ។ លោកជឿថា មិនមានអង្គការក្រៅរដ្ឋាភិបាលណាបដិសេធអំពីសារៈសំខាន់នៃការបោះឆ្នោត និងប្រជាពលរដ្ឋដែលត្រូវទៅបោះឆ្នោតទេ។ រយៈពេលមួយខែក្រោយមកអាចអញ្ជើញអង្គការសង្គមស៊ីវិលមកប្រជុំម្តងទៀត ឱ្យរាយការលទ្ធផលដែលបានចុះទៅជួយផ្សព្វផ្សាយ ។ លោកជឿថាអង្គការក្រៅរដ្ឋាភិបាលមិនបដិសេធទេ មិនថាអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ឬអន្តរជាតិទេ ។

ធនធានទី២. ខាងសាសនា គឺមានវត្ត ព្រះវិហារសាសនាគ្រិស្ត និងព្រះវិហារសាសនាអ៊ិស្លាម ដូច្នេះខាង គខប អាចទាក់ទងជាមួយនឹងធម្មការ ឬមេគុណ និងសាសនាទាំងអស់ ព្រោះមួយថ្ងៃៗអ្នកស្រុកទៅវត្តច្រើន ។ បើសិនជាអាចផ្តល់ដំណឹងតាមវត្តរៀងរាល់ថ្ងៃសិល វិហារសាសនាអ៊ិស្លាមមានចាក់មេក្រូរៀងរាល់ថ្ងៃសុក្រ ដូច្នេះបងប្អូនជនជាតិចាមលោក នឹងបានដឹងអំពីរឿងហ្នឹង វិហារសា សនាគ្រិស្តនៅថ្ងៃសៅរ៍ និងអាទិត្យមានយុវជនចូល ដូច្នេះយុវជនទាំងអស់អាចដឹងដំណឹងពីរឿងហ្នឹងបានដែលអាចឱ្យគេប្រាប់បន្តដល់ក្រុមគ្រួសារ ។

នេះជាដំណោះស្រាយមួយដែលប្រើប្រាស់ធនធានដែលមាននៅនឹងមូលដ្ឋាន ដោយមិនចាំបាច់ចំណាយលុយ ។ ធនធាននេះនឹង អាចជួយបានច្រើនណាស់ ទោះជាការធ្វើអត្តសញ្ញាណប័ណ្ណ និងការបោះឆ្នោតក្តី ឬក៏ដល់ពេលដែលអាចធ្វើនៅក្នុងជិតយុទ្ធនាការបោះឆ្នោតក្តីក៏អាចធ្វើបាន។ ម្យ៉ាងទៀតបើសិនជាការចុះទៅធ្វើអ្វីនៅតាមភូមិមានការខ្លាច មកវត្តជាកន្លែងសន្តិភាពមួយដែលមិនមានអ្នកណាភ័យខ្លាច ព្រោះខ្លះមានលើកជាបញ្ហាថា ការិយាល័យឃុំ និងការិយាល័យគណបក្សនៅជិតគ្នា ពេលណាទៅការិយាល័យឃុំ ចេះតែ ច្រឡំចូលទៅការិយាល័យគណបក្ស ដូច្នេះយើងមានកន្លែងជ្រើសរើសមួយ ។

ទាក់ទងនឹងរឿងដែលបានលើកពីព្រឹកដែលមានការទាស់គ្នាអំពីរឿងអព្យាក្រឹត្យភាព របស់ គជប ឬគខប នៅតាមខេត្ត ។ លោក ជឿថាមិនអាចមានអព្យាក្រឹត្យភាព ១០០ ភាគរយទេនៅស្រុកយើង ព្រោះច្បាប់បានបង្គាប់ឱ្យត្រឹមតែគណបក្សបីទេដែលមានសិទ្ធិ នៅក្នុងការឈរឈ្មោះ ឬមកធ្វើជា គជប ។ ការធ្វើដូច្នេះគណបក្ស ៣០-៤០ នៅក្នុងស្រុកខ្មែរមិនមានឱកាសចូល ។ នៅក្នុងរឿងនេះ ច្បាប់តម្រូវឱ្យមានអព្យាក្រឹត្យភាពនៅត្រឹមប៉ុណ្ណឹង ដូច្នេះប្រទេសយើងគួរតែរៀននៅក្នុងការឱ្យមានអព្យាក្រឹត្យភាពចេញពីមនុស្សដែលអព្យាក្រឹត្យ ។ នៅស្រុកថៃកន្លងមកនេះ ទាក់ទងនឹងការចាប់ គជប យកទៅដាក់ពន្ធនាគារព្រោះតែរឿងមិនអព្យាក្រឹត្យយ៉ាងហោចណាស់ ក៏បង្ហាញការរៀនសូត្រនៅក្នុងការរើសមនុស្សចេញពីប្រភពដែលមិនមែនជាអ្នកកាន់អំណាច ឬជាគណបក្សចូល ។ ឥឡូវ នេះក៏កំពុងតែធ្វើដំណើរការនៅក្នុងការជ្រើសរើសមនុស្សជាកណ្តាល តែកម្ពុជារើសតែមនុស្សចេញពីគណបក្សដែលកាន់អំណាចនៅក្នុងរដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាឃុំ តែគណបក្សដទៃទៀតមិនអាចមានសម្លេងបាន ។ យើងក៏យល់ព្រមថានេះជាដំណើរការនៃការអភិវឌ្ឍន៏ក្នុងស្រុក ប៉ុន្តែយើងក៏មិនភ្លេចនឹងព្យាយាមដើម្បីរៀនសូត្រ និងព្យាយាមសាកល្បងអនុត្តន៏នៅ គជប ថ្នាក់ជាតិ និង

ថ្នាក់ឃុំ ដើម្បីឱ្យមានតម្លាភាព ឬជ្រើសរើសចេញពីក្រុមដែលឯករាជ្យចូលរៀនធ្វើការបណ្តើរៗ ទំរាំថ្ងៃណាមួយប្រទេសយើងអាចនឹងត្រៀមខ្លួនបានសម្រាប់មនុស្សឯករាជ្យទាំងអស់ហ្នឹង ។ នេះជាអនុសាសន៍ ដែលយើងអាចដោះស្រាយបញ្ហាដែលខុសរឿងទំនាក់ទំនងខាងផ្នែកព័តិមានឱ្យបានទៅដល់ដៃប្រជាពលរដ្ឋកាន់តែច្រើនឡើង ។

**លោក ឱក សេរីសោភ័ក្តិ** នៅចំណុចទី ២ ដែលលោកស្នើ នៅក្នុងសង្គមស៊ីវិលទាំងមូលមានចលនានិស្សិត និងយុវជនក៏អាចចូលរួមនៅក្នុងហ្នឹងបានដែរ ហើយជាការស្ម័គចិត្តទៀត ។ តាមដែលលោកបង្រៀនថ្នាក់និស្សិតដើម្បីអប់រំស្មារតីដឹកនាំយុវជនថ្មី គឺអ្នកទាំងអស់ហ្នឹងគាត់ដើរចុះតាមសហគមន៍ ជួយបម្រើច្រើនណាស់ដោយមិនយកលុយកាក់អ្វីទេ ។ ដូចេះបើសិនជា គខប ត្រូវការទៅតាមអ្វី ដែលលោក មណីចិន្តាមានប្រសាសន៍ យើងអាចសម្លឹងមើលថា ស្រុកខ្មែរយើងទាល់តែយើងសម្លឹងមើលប្រភពធនធានរបស់យើងថា នៅកន្លែងណាដែលមានប្រសិទ្ធភាព ហើយអស់លុយតិចមានច្រើនណាស់ ។ ចំណុចទី៣ ជាការប្រសើរណាស់ហើយគណបក្សប្រឆាំង និងសង្គមស៊ីវិលតែងតែទាមទារឱ្យមានអព្យាក្រឹត្យភាពអស់រាប់ឆ្នាំ តាំងពីយន្តការខបសែលលើកទី១ ប្រជុំម្តងណាក៏ទាមទារដែរ ដល់តែទាមទារខ្លាំងពេកទៅមិនរួច ឈប់ទាមទារ ត្រឡប់មកស្នើថាតើរវាងគោលការណ៍អព្យាក្រឹត្យភាព ១០០ ភាគរយ និងគោលការណ៍ តម្លាភាពយកមួយណា ដើម្បីឱ្យឆ្លើយតបនឹងសភាពការពិតនៅកម្ពុជា ។ គាត់ទម្លាក់គោលការណ៍អព្យាក្រឹត្យភាពចោល យកគោលការណ៍តម្លាភាព គឺសុំឱ្យមានការចូលរួម កុំឱ្យ គជប មានតែ ៥ នាក់ ដោយទាមទារឱ្យមានសមាជិកគណបក្សប្រឆាំងចូលដើម្បីឱ្យបានដឹងឮទាំងអស់គ្នា ។ ដូច្នេះប្រទេសនីមួយៗតោងតែមានវិធីដោះស្រាយរៀងៗខ្លួនទៅតាមសភាពការជាក់ស្តែង និងបរិបទសង្គមរៀងៗ ខ្លួន ។ មិនថា គជប នៅអូស្ត្រាលី ជាប្រទេសរបស់លោក Larry Strange អព្យាក្រឹត្យភាព ១០០ ភាគរយ តែម្តង ដោយសារការបោះឆ្នោតជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ អ្នកណាអត់បោះឆ្នោតត្រូវផាក ។ ដូច្នេះ គជប ត្រូវតែជាអាជីពតែម្តង អត់មានរឿងនយោបាយនៅក្នុងហ្នឹងទេ ។ បរិបទនេះគេធ្វើអញ្ចឹងបាន តែយកដំណោះស្រាយហ្នឹងមកដាក់នៅប្រទេសកម្ពុជាធ្វើអត់បាន អញ្ចឹងហើយបានជាការវិវឌ្ឍន៍តោងឈរលើសភាពការជាក់ស្តែងរបស់ប្រទេសនីមួយៗ។ នេះជាការតម្រឹមរបស់គណបក្សប្រឆាំងទៅនឹងស្ថានការជាក់ស្តែង ឥឡូវនេះឃើញលទ្ធផលចេញមកហើយ រាជរដ្ឋាភិបាលគណបក្សកាន់អំណាចក៏ព្រម ។

**លោក ជា ម៉ាច** ជំទប់ទី១ ឃុំចំការសំរោង គណបក្ស សមរង្ស៊ី ឆ្លងតាមការចុះធ្វើការជាក់ស្តែងរយៈពេលជាង ១០ ថ្ងៃ កន្លងមកនេះ ក្នុងការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោត តាមការសង្កេតផ្ទាល់របសលោកមានការលំបាកច្រើន ។ **ទី១.** ខុសឈ្មោះរវាងបញ្ជីឈ្មោះបោះឆ្នោត និងអត្តសញ្ញាណប័ណ្ណ ។ **ទី២.** ប្រជាពលរដ្ឋមួយចំនួនធំគាត់មិនបានទទួលព័តិមាននេះគ្រប់គ្រាន់ទេ មកពីគាត់ទៅរកស៊ីឆ្ងាយ និងក្រុមការងាររបស់សាលាឃុំដែលចុះទៅដើរមិនទាន់សព្វផ្ទះ ហើយជួនជាពេលនេះមានភ្លៀងផង។ ដូច្នេះសំណូមពររបស់លោកគឺនៅពេលដែលយើងចប់រយៈពេលមួយខែនេះសូមឱ្យ គជប ខេត្តជួយបង្ករលក្ខណៈយ៉ាងណាសូមឱ្យគណបក្សនយោបាយមួយៗដែលមាននៅក្នុងមូលដ្ឋានជួយរកអ្នកដែលនៅសេសសល់ ។ ដើម្បីជួយបានសូមឱ្យបង្ករលក្ខណៈថា ឱ្យគណបក្សនយោបាយមួយៗស្រង់ស្ថិតិដែលនៅសល់យើងរកអត់ទាន់ឃើញឱ្យបានអស់ ដើម្បីជួយរកបន្តទៅទៀត ។ មួយទៀតមានខុសអាយុ និងភេទ ចំណុចនេះក៏សុំឱ្យជួយបង្ករលក្ខណៈឱ្យព័តិមានដែលខុស ដល់ដៃគណបក្សនយោបាយឱ្យបានអស់ ដើម្បីឱ្យជួយកែ និងជួយផ្ទៀងនៅពេលដែលយើងបិទបញ្ជីឈ្មោះ ។

លោក **ពុធ កែវ** ប្រធានក្រុមប្រឹក្សាឃុំតារ ស្រុកមោងឫស្សី មកពីគណបក្សប្រជាជន តាមការសង្កេតមួយព្រឹកនេះ បញ្ហាភាគច្រើនចោទមកពីការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត ។ ដោយឡែកនៅស្រុកមោងឫស្សី ជាពិសេសឃុំតារ ក្រោយពីបានទទួលព័ត៌មានពីលេខាធិការដ្ឋានខេត្តឱ្យបញ្ជូនក្រុមប្រឹក្សាឃុំម្នាក់ ដើម្បីទទួលបន្ទុកការងារបោះឆ្នោត ក្នុងនោះឃុំតារបានរើសក្រុមប្រឹក្សាឃុំម្នាក់ ដើម្បីមកចូលរួមប្រជុំទទួលផែនការពី គខប ។ ក្រោយពីបានផែនការ ក្រុមប្រឹក្សាឃុំដែលបានមកចូលរួមប្រជុំក៏បានមករាយការណ៍ជូន លោកដែលជាប្រធានក្រុមប្រឹក្សាឃុំតារ ហើយលោក ក៏បានរៀបចំប្រតិទិនការងារឱ្យមន្ត្រីទទួលបន្ទុកការងារបោះឆ្នោត ដែលបានមកចូលរួមប្រជុំជាមួយ គខប ។ ក្រោយពីបានរៀបចំប្រតិទិនរួចហើយ ក៏បានអញ្ជើញគណបក្សនយោបាយទាំងបីមកចូលរួមប្រជុំ ព្រមទាំងមេភូមិទាំងអស់ក្នុងឃុំមកចូលរួមប្រជុំដើម្បីផ្សព្វផ្សាយ និងទទួលផែនការប្រតិទិនការងារសម្រាប់ចុះទៅផ្សព្វផ្សាយ ជូនប្រជាពលរដ្ឋឱ្យមកចូលរួមក្នុងការមកត្រួតពិនិត្យ កែតម្រូវនៅក្នុងបញ្ជីបោះឆ្នោត ដែលក្រុមប្រឹក្សាឃុំតារចុះទៅធ្វើការតាម ប្រតិទិនដែលបានដាក់ ។ ក្នុងប្រតិទិនសម្រាប់ឃុំតារ ក៏ដូចជាឃុំនានាក្នុងស្រុកមោងឫស្សី ឃុំខ្លះអត់ទាន់បានចុះទៅគ្រប់ភូមិទេដោយ រៀបប្រតិទិនពេញមួយខែទៅតាមកំណត់ របស់លេខាធិការដ្ឋាន ។ ភូមិមួយចំនួនដែលបានចុះទៅមានប្រជាពលរដ្ឋដែលនៅនឹងគេហដ្ឋានបានមកត្រួតពិនិត្យ និងកែតម្រូវទៅតាមឈ្មោះក្នុងបញ្ជីបោះឆ្នោត តែដោយឡែកប្រជាពលរដ្ឋដែលលោកចេញទៅរកស៊ីឆ្ងាយ ដោយរដូវនេះជារដូវបង្កបង្កើនផលផង ហើយលោកមិនសូវមានមុខនៅផ្ទះទេ ពេលដែលមន្ត្រីយើងចុះទៅដល់ភូមិនីមួយៗមេភូមិ និងជំនួយការភូមិទាំងបីរូប ព្រមទាំងក្រុមប្រឹក្សាឃុំដែលចុះទៅ ជិះម៉ូតូទៅតាមគ្រួសារនីមួយៗ ។ ប្រតិទិនរបស់លេខាធិការដ្ឋានខេត្តមានពេលកំណត់ បើយើងគិតពីការដើរទៅតាមផ្ទះ គឺមិនឆ្លើយតបទៅនឹងផែនការកំណត់របស់ គជប ទេ ។ អញ្ចឹងយើងកំណត់ក្នុងមួយភូមិទៅតាមមេភូមិដែលកំណត់ឱ្យថា កន្លែងណាដែលប្រមូលផ្តុំជិតៗ ។ កន្លងមកលទ្ធផលនៃការចុះផ្តល់ព័ត៌មានក្នុងការបោះឆ្នោតជូនប្រជាពលរដ្ឋសម្រាប់ឃុំតារ ដូចជាមិនមានបញ្ហាអ្វីចោទឡើងទេ គឺដំណើរការដោយរលូន ។ ចំពោះគណបក្សនយោបាយទាំងបី ក៏បានផ្សព្វផ្សាយថា អស់លោកដែលអញ្ជើញមកប្រជុំនេះសូមផ្សព្វផ្សាយព័ត៌មាននេះទៅដល់សមាជិករបស់អស់លោក និងជួយបញ្ជូនសមាជិកដើម្បីមកត្រួតពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងកែតម្រូវ ។ ដូច្នេះឃើញថាបើកសិទ្ធិទូលំទូលាយណាស់ ហើយពេលដែលចុះទៅ អត់មានកំណត់ថាជាសមាជិកខាងណាៗនោះទេ ព្រោះមន្ត្រីសមាជិកក្រុមប្រឹក្សាឃុំតារអត់ស្គាល់ថាអ្នកណាជាសមាជិកណានោះទេ គឺយើងធ្វើជាទូទៅ ឱ្យតែលោកបាន អញ្ជើញមកត្រួតពិនិត្យ តែលទ្ធផលនៅតែមានសេសសល់ ។

លោក **ឱក សេរីសោភក្តិ** ចំណុចចុងក្រោយដែលលោក ពុធ កែវ មានប្រសាសន៍ តាមដែលបានស្តាប់ប្រសាសន៍របស់ លោក វ៉ន ពន គឺប័ណ្ណព័ត៌មាននៅទីនោះ ដូច្នេះចំពោះប្រជាពលរដ្ឋដែលចំណាកស្រុកទៅ ហើយពេលដែលលោកត្រឡប់ពីធ្វើការវិញអាចនឹងទៅរកនៅកន្លែងនោះបាន ។ ដូច្នេះសុំកុំកំណត់ត្រឹមតែមួយខែ ចេះតែបន្តទៀតទៅនៅក្នុងរឿងចែកប័ណ្ណព័តមានអ្នកបោះឆ្នោតនេះ ។ ហេតុផលរឿងបងប្អូនធ្វើចំណាកស្រុក រដូវភ្លៀងធ្លាក់ ធ្វើការបង្កបង្កើនផលនិងទៅរកស៊ី ស្ទើរតែគ្រប់គ្នាហើយ ជាការធម្មតា យើងមិនអាចកំណត់ពេលឱ្យគាត់តែមួយខែបានទេ ដូច្នេះមានការដោះស្រាយ ។ បញ្ហាដែលលើកឡើងដោយលោក មណីចិន្តា ប្រសិនបើយើងសហប្រតិបត្តិការជាមួយវត្ត ការផ្សព្វផ្សាយព័ត៌មានអាចនឹងបានទូលំទូលាយ ដូច្នេះសុំស្នើទៅខាង គខប ឱ្យពិនិត្យមើល លទ្ធភាពនេះ ។

**លោក វ៉ន ពន** លោកបានធ្វើការចាប់អារម្មណ៍ និងអរគុណចំពោះចំណុចដែលលោក ហេង មណីចិន្តា បានលើកឡើង ។ បញ្ហានេះយើងបានធ្វើការជាប្រចាំហើយជាមួយ អង្គការក្រៅរដ្ឋាភិបាល និងជាមួយគណបក្សនយោបាយ ព្រមទាំងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលស្ថិតនៅក្នុងរង្វង់ខេត្តបាត់ដំបងនេះ ។ ដូចជាមុនការផ្សព្វផ្សាយក្នុងការចែកប័ណ្ណអ្នកបោះឆ្នោតនេះ ក៏យើងបានធ្វើការអញ្ជើញគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់មកជម្រាបពីពេលវេលា និងផលប្រយោជន៍នៃការចែកប័ណ្ណនេះ យើងបានសហការជាមួយធនធានមនុស្សដែលមាននៅក្នុងកន្លែង ។ ម៉្យាងទៀតដូចជាកាលពីឆ្នាំ ២០០៣ គខប បានធ្វើការសុំឱ្យលោកអាចារ្យនៅតាមវត្ត ជួយធ្វើការផ្សព្វផ្សាយនៅពេលដែលបោះឆ្នោត តែអនុវត្តបានដោយអន្លើនៃឃុំខ្លះទេ ។ ឃុំបានធ្វើការផ្សព្វផ្សាយគ្រប់រូបភាព តាមម៉េក្រូ តាមផ្លូវថ្នល់ វត្តអារ៉ាម វិហារផ្សេងៗ តែមិនទាន់បានទូលំទូលាយទេព្រោះពេលវេលាមានកំណត់ តែនេះជាសំនូមពរមួយ ដូច្នេះ គខប នឹងយកសំនូមពរនេះទៅពិនិត្យ និងធ្វើការអនុវត្តទៅតាមសំនូមពរនេះ ព្រោះនេះជាបញ្ហាគន្លឹះមួយ ។ សូមបញ្ជាក់ថា ការផ្សព្វផ្សាយពីមុនជាការធ្វើដោយប្រយោលទេ តែឥឡូវនេះយើងចែកប័ណ្ណបោះឆ្នោតជូនដល់អ្នកបោះឆ្នោត គឺជាការអញ្ជើញគាត់ដោយផ្ទាល់ទៅបោះឆ្នោត នេះជាការផ្សព្វផ្សាយមួយដោយផ្ទាល់ ។ នេះជាបញ្ហាមួយដែល គជប ធ្វើការកែទម្រង់នីតិវិធីនៃការផ្សព្វផ្សាយ ។

បញ្ហាដែលលោក ជា ម៉ាច បានលើកឡើងជាសំនូមពរសុំឱ្យគណបក្សនយោបាយបានដឹងឈ្មោះប្រជាពលរដ្ឋដែលពុំទាន់បានទទួលប័ណ្ណព័តិមានបោះឆ្នោត ។ ការងារនេះអាចធ្វើទៅបាននៅពេលក្រុមប្រឹក្សាឃុំដែលទទួលបន្ទុកការចែកប័ណ្ណនេះយកប័ណ្ណមកសាលាឃុំហើយ គណបក្សនយោបាយអាចសុំបើកមើល និងកត់ឈ្មោះអ្នកដែលពុំទាន់បានទទួល បើស្គាល់អ្នកណាគណបក្សនយោបាយអាចជម្រាបសាម៉ីខ្លួនឱ្យមកទទួលនៅសាលាឃុំបាន ។លើកលែងតែសុំហែកយកទៅឱ្យផ្ទាល់មិនបានទេ សមីខ្លួនត្រូវតែទទួលដោយផ្ទាល់ ឬមួយតំណាងរបស់សាម៉ីខ្លួនដូចជាប្តី ប្រពន្ធ កូន ឬឪពុកម្តាយជាដើម អាចមកទទួលជំនួសបាន ។ នីតិវិធីនៃការទទួល អ្នកដែលតំណាង ទទួលដោយដាក់ឈ្មោះខ្លួនឯង ឬផ្តិតមេដៃ។ ជាសំណូមពរ សូមឱ្យគ្រប់គណបក្សនយោបាយជួយក្នុងបញ្ហានេះ ព្រោះ គខប ជឿថាក្នុង មួយខែនេះចែកមិនអស់ទេ ។ គោលបំណងរបស់ការចែកប័ណ្ណនេះ គឺចង់ឱ្យប្រជាជនដឹងថាគាត់នៅការិយាល័យណា ឈ្មោះរបស់គាត់ ត្រឹមត្រូវឬទេ ទិន្នន័យផ្សេងៗត្រឹមត្រូវឬទេ ។ នៅខេត្តបាត់ដំបងនេះទិន្នន័យផ្សេងៗខុសច្រើន ដូចជាអាស័យដ្ឋានជាដើម នេះជាទិន្ន័យ មួយ ដែលស្មៀនត្រូវតែធ្វើការកែតម្រូវនៅពេលដែលចុះឈ្មោះបោះឆ្នោតក្នុងខែ ១០ នេះ ។ ពេលដែលចុះឈ្មោះ ឬភេទក៏នៅក្នុងបញ្ហា ហ្នឹងដែរ ប្រជាពលរដ្ឋអាចពិនិត្យមើលបាន ពេលដែលខុសអ្នកទទួលបន្ទុកនឹងកែនៅកន្ទុយប័ណ្ណ ដល់ពេលចុះឈ្មោះមែនទែន ស្មៀននឹង យកទៅធ្វើការកែតម្រូវនៅក្នុងបញ្ជី។ គណបក្សនយោបាយអាចតាមដានមើលបានថា តើស្មៀនបានកែតម្រូវហើយឬនៅ បើបានកែតម្រូវហើយមិនជាបញ្ហាទេ តែប្រសិនបើពេលបិទបញ្ជីដំបូងឈ្មោះដែលខុសមិនទាន់បានកែតម្រូវ សាម៉ីខ្លួនអាចកែតវ៉ាបាន ។ នេះជា សារៈប្រយោជន៍នៃការបិទបញ្ជីដំបូង ហើយបើបានគណបក្សនយោបាយទាំងអស់មានស្មារតីជួយសំរួលការងារនេះ គខប សូមថ្លែង អំណរគុណទុកជាមុន ។

លោក **ឱក សេរី សោភក្តិ៍** ដោយមានការគាំទ្រយ៉ាងសស្រាក់សស្រាំ លោក Douglas Gardner ជាប្រធាន UNDP នៅប្រទេសកម្ពុជា លោកនឹងចូលរួមពិនិត្យជាអ្នកសង្កេតការណ៍ក្នុងខេត្តកំពង់ឆ្នាំង ថាតើការចូលរួមផុសផុលយ៉ាងណា លើយន្តការខប់សែល នេះ ។ បន្ថែមពីហ្នឹងទៀត អង្គការស៊ីដា របស់ប្រទេស ស៊ុយអែត ដែលជាអ្នកគាំទ្រលើការបោះឆ្នោតគ្រប់ៗលើកទាំងអស់តំណាងលោកពីរនាក់ នឹងមកចូលរួមជាអ្នកសង្កេតការណ៍ដែរ ថាតើ ជីវិតរស់រវើកនៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជាតាម

រយៈយន្តការខប់សែលនេះយ៉ាងណា។ មួយខែម្តងមានប្រជុំនៅ UNDP ជាមួយឯកឧត្តម អ៊ឹម សួស្តី និងខាងប្រទេសអ្នកផ្តល់ជំនួយទាំងអស់ ។ ក្នុងឋានៈជាអ្នកសម្របសម្រួលខប់សែល លោកក៏បានអញ្ជើញទៅដែរ ហើយម្តងៗយើងតែងតែរាយការណ៍ជូនប្រទេសអ្នកដែលផ្តល់ជំនួយទាំងអស់នោះ ហើយប្រទេសទាំងអស់នោះគាត់រំភើប ណាស់ចំពោះការដែលយើងអាចជជែកគ្នានៅថ្នាក់មូលដ្ឋានដោយសន្តិវិធីបាន បញ្ហាក្តៅគគុកយ៉ាងណាក៏យើងអាចជជែកនៅក្នុងអាកប្បកិរិយាថ្លៃថ្នូរបានដែរ ដោយព្រោះអញ្ចឹងហើយបានជាគាត់ចង់អញ្ជើញមកមើលផ្ទាល់ ។ ខប់សែល សូមជម្រាបអាជ្ញាធរដែនដីគ្រប់ ជាន់ថ្នាក់ដែរអំពី បញ្ហាមួយដែលពួកប្រទេសផ្តល់ជំនួយលើកពីរដងរួចមកហើយក្នុងខែ កក្កដា និងសីហា គឺបញ្ហាមេភូមិខ្លាំងមែនទែន ។ មានពីររឿងដែលប្រទេសម្ចាស់ជំនួយលើកឡើងដល់តំណាងក្រសួងមហាផ្ទៃ និង គជប ទី១. មិនអាចចាត់តាំងមេភូមិមួយជីវិតអញ្ចឹងបានទេ ព្រោះនៅក្នុងចំណាត់ការរបស់ក្រសួងមហាផ្ទៃគឺទាល់តែមេភូមិឈឺ ឬអសមត្ថភាពទើបអាចជំនួសបាន បើមិនអញ្ចឹងទេមេភូមិ អត់មានអណ្តតិបញ្ចប់ទេ លក្ខណៈនេះការតិះទៀនច្រើនណាស់ពីសហគមន៍អន្តរជាតិ ។ ទី២. គាត់បានទទួលដំណឹងថាមេភូមិភាគច្រើន ទទួលការតែងតាំងភ្លាមធ្វើសមត្ថភាពបានល្អខ្លាំងណាស់ មានលក្ខណៈជាវិជ្ជមានជួយដល់ភូមិច្រើន ប៉ុន្តែមានមេភូមិមួយចំនួនកើតឡើងភ្លាម គាត់ដើរសំឡុតតាមផ្ទះ ។ ដូច្នេះហើយសហគមន៍អន្តរជាតិ និងសង្គមស៊ីវិលនឹងតាមដានមើលអាកប្បកិរិយារបស់មេភូមិនៅយន្តការបោះឆ្នោតព្រោះ បញ្ហានេះសំខាន់ណាស់មេភូមិជាមនុស្សគន្លឹះតែម្តង ។ ខ្ញុំបានចុះទៅគេងនៅតាមភូមិឃុំ ប្រជាពលរដ្ឋមិនសូវទៅឃុំប៉ុន្មានទេ ។ លោកបានចុះទៅចូលរួមក្នុងសមាហរណកម្មគម្រោងអភិវឌ្ឍន៍ មេភូមិមានតួនាទីរបស់គាត់ជាចលករ មួយនៅក្នុងភូមិ មានកិច្ចប្រជុំក៏ធ្វើនៅផ្ទះមេភូមិ ព័ត៌មានក៏ចែកចាយនៅផ្ទះមេភូមិដែរ មួយខែម្តងដែលប្រជាពលរដ្ឋត្រូវឡើងទៅដល់ឃុំដើម្បីប្រជុំពួកគាត់មិនទៅទេ តែបើនៅផ្ទះមេភូមិប្រជាពលរដ្ឋទៅ ។ អញ្ចឹងហើយបានជាមេភូមិដើរតួនាទីសំខាន់ណាស់នៅក្នុងជីវិត ប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ដូច្នេះភ្នែកដែលសង្កេតអាកប្បកិរិយារបស់មេភូមិនឹងមានច្រើន ទាំងភ្នែកជាតិ និងអន្តរជាតិ ។

ខប់សែល បានទទួលពីអាជ្ញាធរខេត្ត អាជ្ញាធរស្រុក និងពីក្រសួងមាហាផ្ទៃហើយអំពីបញ្ហាមួយដែលរៀងរាល់ពេលបោះឆ្នោតមានវត្តមានរបស់អាជ្ញាធរមូលដ្ឋាននៅជុំវិញស្ថានីយបោះឆ្នោត ។ គ្រប់ខេត្តទាំងអស់ដែលខប់សែលបានជួប ក្រសួងមហាផ្ទៃក៏បានឯកភាពដែរ គឺសូមឱ្យលោកមេភូមិ មេស្រុក ឬក្រុមប្រឹក្សាឃុំសង្កាត់នៅពេលដែលបោះឆ្នោតហើយឱ្យអញ្ជើញទៅផ្ទះវិញ ជៀសវាងការឈរនៅរេរានៅកន្លែងការិយាល័យបោះឆ្នោតទៀត ព្រោះអត់មានចំណេញបានតែគេតិះទៀន ។ នៅក្នុងសេចក្តីរាយការណ៍របស់អ្នកសង្កេតការណ៍តែងតែតិះទៀន អញ្ចឹងចាប់ពីពេលនេះទៅកុំឱ្យមានទៀត ។ មួយទៀតបញ្ហានៅពពាក់ពពូនគ្នា ២-៣ ម៉ោងពេលដែលចាប់ផ្តើមបោះឆ្នោតដំបូង រឿងដែលកើតឡើងនេះជាបញ្ហាគន្លឹះ រៀបរយឬអត់ គឺនៅពេលហ្នឹងហើយ ។ អញ្ចឹងហើយបានជាខប់សែល ស្វាគមន៍ដល់ គជប ដែលបន្ថែមបុគ្គលិកម្នាក់ទៀតនៅមុខការិយាល័យបោះឆ្នោត កាលមុនមានតែ ៥ ឥឡូវមាន ៦ នាក់ ។ ម្នាក់ដែលបន្ថែមនេះហើយដែលជាអ្នកណែនាំប្រជាពលរដ្ឋដែលទៅបោះឆ្នោត កុំឱ្យមេភូមិ ឬក្រុមប្រឹក្សាឃុំ-សង្កាត់ ជាអ្នកដើរចង្អុលបង្ហាញ ដែលមិនមែនជាតួនាទីទេ ហើយមិនមានលក្ខណៈឯករាជ្យ និងមិនអាចទទួលយកបាន ។ ដូច្នេះចំណាត់ការរបស់ គជប នេះត្រឹមត្រូវណាស់ដែលបានថែមបុគ្គលិកម្នាក់ទៀតដើម្បីជួយអ្នកបោះឆ្នោត ។

បញ្ហាមួយទៀតលោកសូមឯកភាពជាមួយប្រសាសន៍របស់លោក មណីចិន្តា អំពីតួនាទីរបស់សង្គមស៊ីវិលនៅ ក្នុងយន្តការបោះឆ្នោតនេះធំធេងណាស់ ហើយទទួលស្គាល់ដោយសហគមន៍អ្នកផ្តល់ជំនួយ ។ បើសិនជាខាង គខប អាចនឹងធ្វើសហប្រតិបត្តិការបានគួរតែបើកទូលាយចំហរធ្វើសហប្រតិបត្តិការជាមួយ មិនមែនតែអង្គការក្រៅរដ្ឋាភិបាលទេ គឺសង្គមស៊ីវិលទាំងមូលតែម្តង។ សាលារៀន និងខាងផ្នែកឯកជនទាំងអស់ត្រូវប្រមូលគ្នាដើម្បីនឹងគាំទ្រយន្តការនៃការរៀបចំការបោះឆ្នោត ។

លោក **សឿម ឆម** ជំទប់ទី២ ឃុំរកា មកពីគណបក្សសមរង្ស៊ី មានចំណុចពីរ ទី១. អត្តសញ្ញាណប័ណ្ណដែលធ្វើបានហើយ ផ្តល់ទៅឱ្យខាងប៉ូលីសនៅឃុំរកា ហេតុដូចម្តេចបានជាមិនចែកទៅដល់ប្រជាពលរដ្ឋ ហើយធ្វើជាកម្មវិធីចែកចាយវិញ? ទី២. ពេលចុះឈ្មោះបោះឆ្នោត សូមឱ្យគណៈកម្មាការជាតិដែលរៀបចំនៅក្នុងឃុំរកាមានអព្យាក្រឹត្យភាព និងតម្លាភាព មិនរើសអើងនៅក្នុងការចុះឈ្មោះបោះឆ្នោត ។ បញ្ហាចុះឈ្មោះបោះឆ្នោតនេះ មេភូមិបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទៅតាមភូមិនីមួយៗ តែបែរជាផ្សព្វផ្សាយទៅតាមសមាជិករបស់គាត់ ។ ក្នុងការចុះឈ្មោះ លោកក៏បានទទួលការគាំទ្រពីអង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ដែលមានលោកហេង មណីចិន្តា ជានាយក ជារៀងរាល់ឆ្នាំ ។ ប៉ុន្តែពេលដែលចុះធ្វើអន្តរាគមន៍ លោកមេភូមិធ្វើព្រងើយកន្តើយដូចជាមិនចាប់អារម្មណ៍នៅក្នុងការចុះឈ្មោះ ។

លោក **ប៉ូច ភាង** ប្រធានក្រុមប្រឹក្សាឃុំស្តៅ ស្រុករតនៈមណ្ឌល ការដែលយើងរៀបចំផ្តល់ប័ណ្ណព័ត៌មានជូនប្រជាពលរដ្ឋជាការងារថ្មី ដូច្នេះគ្រប់ឃុំទាំងអស់បានរៀបចំចាត់តាំងតំណាងក្រុមប្រឹក្សាឃុំ តាមឃុំនីមួយៗ ដើម្បីមកទទួលព័ត៌មានពីលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត ក្នុងការរៀបចំផ្សព្វផ្សាយ និងចែកជូនប័ណ្ណដល់ប្រជាពលរដ្ឋ ។ ការងារនេះឃុំបានរៀបចំធ្វើកាលវិភាគច្បាស់លាស់ ដោយឱ្យតំណាងក្រុមប្រឹក្សាឃុំ ចុះទៅតាមភូមិ ព្រោះឃុំខ្លះភូមិតិច ខ្លះច្រើន ជាក់ស្តែងឃុំស្តៅមានរហូតដល់ ១៦ ភូមិ ។ អញ្ចឹងកាលវិភាគក្រុមការងាររៀបចំរយៈពេលមួយខែ ភូមិខ្លះបានពេលតែ ២ ទៅ ៣ ថ្ងៃទេ ។ ពាក់ព័ន្ធនឹងការផ្សព្វផ្សាយ គួរតែយើងទាំងអស់គ្នាកុំឱ្យមានពាក្យចោទប្រកាន់គ្នា ព្រោះការផ្សព្វផ្សាយយើងដឹងទាំងអស់គ្នា ។ និយាយដោយឡែកឃុំស្តៅ មានបីគណបក្សដែលចូលរួមជាក្រុមប្រឹក្សាឃុំ ដូច្នេះទាំងបីនាក់បានដឹងទាំងអស់គ្នា ហើយគួរតែទាំងអស់គ្នាជួយផ្សព្វផ្សាយដល់សមាជិក ។ លោកសូមហៅថា សមាជិក ព្រោះការបោះឆ្នោតទាល់តែមានការគាំទ្រពីសមាជិក អញ្ចឹងទាំងអស់គ្នាគួរតែផ្តល់ព័ត៌មានតាមសមាជិក នៅតាមភូមិនីមួយៗ ដើម្បីត្រៀមចាំទទួលព័ត៌មានពេលដែលក្រុមការងារចុះ ។ ពាក់ព័ន្ធនឹងការងារចុះឈ្មោះបោះឆ្នោត កន្លងមកគណៈកម្មាធិការរៀបចំការបោះឆ្នោត បានបង្កើតក្រុមការងារចុះឈ្មោះបោះឆ្នោត ដែលមាន PEC និង CEC ជាដើម តែក្រោយពីការជ្រើសរើសក្រុមប្រឹក្សាឃុំចូលកាន់តំណែង បន្ទុកការចុះឈ្មោះបោះឆ្នោតធ្លាក់មកលើក្រុមប្រឹក្សាឃុំ និងស្មៀន ដែលនាំឱ្យមានបញ្ហាពាក់ព័ន្ធមួយចំនួន ជាមួយនឹងឯកសារដែលត្រូវចុះឈ្មោះ ។ ប្រជាពលរដ្ឋមួយចំនួនអត់មានឯកសារ ឧទាហរណ៍ ដូចជាប្រជាជន ទើបតែផ្លាស់ប្តូរទីលំនៅ ពេលដែលគាត់មកចុះឈ្មោះ គោលការណ៍របស់ គជប ត្រូវពិនិត្យមើលលើឯកសារសំគាល់ គាត់អត់មាន ។ អញ្ចឹងត្រូវជំរុញគាត់ឱ្យមកផ្តល់ព័ត៌មាននៅប៉ុស្តិ៍រដ្ឋបាល ដើម្បីមកសុំចុះឈ្មោះជាអចិន្ត្រៃនៅប៉ុស្តិ៍សិន បានឯកសារពី ប៉ុស្តិ៍មកទើបក្រុមប្រឹក្សាឃុំចុះឈ្មោះគាត់ នៅក្នុងការិយាល័យបោះឆ្នោត។ ដូច្នេះបញ្ហានេះគ្រប់គណបក្សនយោបាយគួរតែចេះសម្រប សម្រួលការងារទៅវិញទៅមក ត្រូវផ្តល់ព័ត៌មានដល់សមាជិកខ្លួន ។ សិក្ខាសាលាថ្ងៃនេះនិយាយអំពីការបង្ការទំនាស់នៅពេលបោះ ឆ្នោតខាងមុខ បញ្ហាកើតច្រើនមាននៅមូលដ្ឋាន ដូច្នេះថ្នាក់ដឹកនាំនៅមូលដ្ឋានគួរតែពិភាក្សាគ្នានៅថ្នាក់មូលដ្ឋាន ព្រោះឃុំនីមួយៗមាន គណបក្សនយោបាយចំរុះកំពុងតែធ្វើការជាមួយគ្នា បើមានសមាជិកណាពិនិត្យឃើញបញ្ហាអ្វីមួយគួរតែពិភាក្សាគ្នាក្នុងកិច្ចប្រជុំមួយ ដើម្បីពិភាក្សារកនីតិវិធីដោះស្រាយ ។ ជាសំណូមពរសូមឱ្យគ្រប់គណបក្សនយោបាយទាំងអស់ ធ្វើយ៉ាងណាសហការគ្នាក្នុងការអនុវត្ត ការងាររួម ព្រោះការងារបោះឆ្នោតនេះជាការងាររួម ហើយកុំឱ្យចោទប្រកាន់ថាអាជ្ញាធរគ្មានតម្លាភាព ។ បើសិនជាឃើញអាជ្ញាធរណា មួយលម្អៀង ហើយការអនុវត្តន៍ជាក់ស្តែងមានភស្តុតាងត្រឹមត្រូវទាំងអស់គ្នាអាចធ្វើពាក្យបណ្តឹងបាន អញ្ចឹងយើងកុំគិតតែពីរឿងចោទ ប្រកាន់គ្នាទៅវិញទៅមក គោរងគិតពីការងាររួមរបស់ប្រទេសជាតិយើងទាំងអស់គ្នា តើយើងគួរធ្វើខ្លះនៅចំពោះមុខ ។

លោក **ឱក សេរីសោភក្តិ៍** នៅពេលថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតមានខេត្តជាច្រើនបានលើកពីបញ្ហានេះ ហើយមួយព្រឹកនេះ ខប់សែល អត់ទាន់បានឮទេ ។ សូមឱ្យតំណាងគណបក្សនយោបាយទាំងអស់ដែលជាអ្នកសង្កេតការណ៍នៅស្ថានីយបោះឆ្នោត ទោះបីជាលទ្ធផលមិនបានពេញចិត្តក្តី តែកាតព្វកិច្ចរបស់យើងត្រូវនៅឱ្យចប់ចុងចប់ដើម ។ មានតំណាងគណបក្សច្រើនណាស់ ដែលដើរចេញពីស្ថានីយរាប់សន្លឹកឆ្នោតមុនការប្រកាសលទ្ធផល ។ បែបបទនីតិវិធីដែលត្រូវចុះហត្ថលេខារួមដោយតំណាងគណបក្ស ទោះបីជាចាញ់ ឬឈ្នះក៏ដោយ ក៏តួនាទី និងការទទួលខុសត្រូវកុំលាយឡំគ្នា គណបក្សនយោបាយទាំងអស់ត្រូវឱ្យនៅចប់ចុងចប់ដើម ។ បញ្ហានេះមានខេត្តច្រើនណាស់ បានឡើង ដូច្នេះក្នុងឋានៈយន្តការ ខប់សែល សូមមេត្តាជម្រាបជូនដល់គណបក្សទាំងតូច ទាំងធំថា តួនាទីរបស់គណបក្សនយោបាយត្រូវនៅឱ្យចប់ចុងចប់ដើម ដើម្បីបំពេញបែបបទ ។

លោក **សួន ចំរើន** សមាជិកគណបក្សសមរង្ស៊ី មុននឹងចូលដល់សំណួរ លោកសូមលើកជាសំនួមពរដល់អស់លោក លោកស្រីដែលមានវត្តមាននៅទីនេះ ដែលជាខ្មែរសូមឱ្យមានវប្បធម៌មួយ គឺនិយាយហើយធ្វើ ។ បើគាត់មានសមត្ថកិច្ច មានសិទ្ធិអំណាចនៅក្នុងការអនុវត្តន៍កាតព្វកិច្ច និងតួនាទីទាំងអស់សូមឱ្យធ្វើ ។ បើសិនជាគណបក្សសមរង្ស៊ីមានសិទ្ធិអំណាច និងសមត្ថកិច្ចក្នុងការអនុវត្តគណបក្ស សមរង្ស៊ី ក៏ធ្វើដែរ ។ ឆ្លងតាមរយៈការប្រជុំនេះ គឺតំណាងខាងស្នងការដ្ឋាន និងលោកតំណាងខាងលេខធិការដ្ឋានសុទ្ធតែមានគំនិតល្អៗ ក៏ប៉ុន្តែកន្លងមកនេះគណបក្ស សមរង្ស៊ី សង្កេតឃើញថាមិនទាន់បានអនុវត្ត កុំថាឡើយឱ្យល្អ ១០០ ភាគរយ សូមឱ្យតែមានលក្ខណៈមួយដែលអាចទទួលយកបាន ក៏មិនមានដែរ គឺនៅមានកម្រិត ។ តួយ៉ាងដូចលោក សុខ តុលា ដែលជាតំណាងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង លោកមានប្រសាសន៍ គណបក្ស សមរង្ស៊ី សូមគាំទ្រនូវសម្តីដែលលោកលើកឡើងថា ប្រជាពលរដ្ឋខ្មែរទាំងអស់មានសិទ្ធិធ្វើអត្តសញ្ញាណប័ណ្ណខ្មែរ ដោយមិនបាច់បង់ប្រាក់ ។ មិនមែនត្រឹមតែស្នងការទេ គឺអគ្គស្នងការ និងស្នងការសុទ្ធតែនិយាយបែបនេះទាំងអស់ ក៏ប៉ុន្តែរឿងនេះមិនមែនទើបតែនិយាយពេលបច្ចុប្បន្ននេះទេ គឺមានតាំងពីយូរណាស់មកហើយ ប៉ុន្តែការអនុវត្តគឺគ្មានសារះ នៅតែទារលុយដដែល ។ ដូចជានៅឃុំជ្រៃ ៣៥០០ រៀល គួរសមហើយ ចំណែកនៅស្រុកមោង និងឃុំផ្សេងទៀតទារដល់ទៅ ១៥០០០ រៀល លោកបានចុះជួបផ្ទាល់ជាមួយប្រជាពលរដ្ឋ ព្រោះលោកធ្វើការជាក្រុមការងារប្រចាំខេត្តបាត់ដំបង ដូច្នេះបើមានទ្រឹស្តី សូមឱ្យមានការអនុវត្តផង ។ អត្តសញ្ញាណប័ណ្ណនេះសំខាន់ណាស់ ព្រោះគាត់ខ្មែរតែអត់មានអត្តសញ្ញាណប័ណ្ណខ្មែរ បញ្ហានេះគួរឱ្យខ្មាស់ប្រទេសជិតខាងដែលពលរដ្ឋគេមានអត្តសញ្ញាណប័ណ្ណពលរដ្ឋគេ ។ សូមសួរសំណួរដែលទាក់ទងទៅនឹងកម្មវិធី ខប់សែល ដែល លោកពិនិត្យឃើញថាមានបីដំណាក់កាល គឺដំណាក់កាលមុនការបោះឆ្នោត ពេលបោះឆ្នោត និងក្រោយការបោះឆ្នោត ។ លោកយល់ថាការបោះឆ្នោតនេះមិនទាន់មានតម្លាភាព កាលពីមុនគណបក្សប្រឆាំងទាមទាររកអព្យាក្រឹត្យ តែអត់ទាន់បាន ដូច្នេះសូមទាមទារយកតម្លាភាព ។ ក្នុងនោះដែរអត់ទាន់មានតម្លាភាពទេ តួយ៉ាងដូចជាការបោះឆ្នោត ព្រឹទ្ធសភា នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០៦ ដែលរូបលោកបានចូលរួមដែរ សង្កេតឃើញលើការគូសសញ្ញា ខាង គជប បាន បញ្ជាក់ថា បើសញ្ញាណាដែលធ្វើឱ្យសំគាល់ដល់បុគ្គលដែលបោះ មិនអាចទទួលយកទេ ។ ប៉ុន្តែនៅខេត្តបាត់ដំបងមានគូសសញ្ញា ដូចជា សញ្ញា "O" សញ្ញាខ្វែង និងមានប្រតាកទឹក ពោលគឺមានសញ្ញាលើសពី១ ហើយបញ្ហាពីអត្តសញ្ញាណរបស់បុគ្គលដែលគូសឱ្យគេនៅតែទទួលយក ។ គណបក្ស សមរង្ស៊ីបានធ្វើជាការប្តឹង ប៉ុន្តែគ្មានការដោះស្រាយទេ នេះបង្ហាញថា គជប មិនទាន់មានតម្លាភាព និងអព្យាក្រិត្យនៅឡើយ ហើយនៅតែមានទំនោរទៅរកគណបក្សកាន់អំណាចដដែល ។ តាមរយៈអង្គប្រជុំ លោកសង្កេតឃើញថាប័ណ្ណព័តិមានសំខាន់ណាស់ ព្រោះប័ណ្ណនេះផ្តល់ទៅដើម្បីឱ្យ

ប្រជាពលរដ្ឋខ្មែរទាំងអស់ស្គាល់ពីទីតាំងការិយាល័យ និងលេខរៀងពីការបោះឆ្នោត ។ បើគ្មានប័ណ្ណព័ត៌មាន ហើយកាន់តែប័ណ្ណណាមួយក្នុងចំណោមប័ណ្ណទាំង ១០ យកទៅ គឺនៅតែអត់ដឹង ហើយអត់បានបោះដដែល អញ្ចឹងប័ណ្ណព័ត៌មាននេះសំខាន់ណាស់ ។ មកដល់ថ្ងៃនេះ គឺរយៈពេល ១៦ ថ្ងៃ ឃើញថាការចែកប័ណ្ណព័ត៌មាននេះនៅមានចំនួនតិចមែនទែន ដូចជាឃុំរតនៈ បានតែជាង ១០ ភាគរយ ដូច្នេះក្នុងពេលមួយខែបានយ៉ាងច្រើន ៣០ ភាគរយ នៅសល់ ៧០ ភាគរយ ទៀតដល់ថ្ងៃបោះឆ្នោតអត់បាន ទៅបោះឆ្នោតទេ ព្រោះប័ណ្ណបោះឆ្នោតទុកជានិរាករ និងអស់សុពលភាព ។ មុនការចែកប័ណ្ណ លេខាធិការដ្ឋានបានអញ្ជើញអស់លោក ដែលជាក្រុមប្រឹក្សាឃុំទាំងអស់ទៅចូលរួមប្រជុំ ហើយពន្យល់បង្រៀនពីការចែកប័ណ្ណព័ត៌មានដល់ក្រុមប្រឹក្សាឃុំសង្កាត់ទៀត ប៉ុន្តែខ្ញុំ មិនយល់ថាតើមកពីសិស្សអត់យកចិត្តទុកដាក់ ឬក៏គ្រូបង្រៀនគ្មានសមត្ថភាព ។ ដូចដែលលោក ប្រធានលេខាធិការដ្ឋានមាន ប្រសាសន៍ការចែកប័ណ្ណនេះអត់មានផ្តិតមេដៃ មួយទៀតសាម៉ីខ្លួនទៅរកស៊ីឆ្ងាយ អ្នកចែកប័ណ្ណអាចឱ្យមេគ្រួសារ ឬអ្នកណាដែលជា សមាជិកនៃគ្រួសារទទួលជំនួសបាន ប៉ុន្តែមិនបានធ្វើដូច្នេះទេ មានការទាមទារយកអត្តសញ្ញាណប័ណ្ណទៅទើបបានអ្នកចែកប័ណ្ណផ្តល់ឱ្យ ។ មួយទៀតការឱ្យតំណាងគណបក្សទៅជាមួយ លោកបានបញ្ជូនតំណាងគណបក្សទៅឃុំមួយចំនួន គឺអ្នកចែកប័ណ្ណចែកជូន តែឃុំ មួយចំនួនច្រើនទៀតបដិសេធចោល ដោយមិនទទួលយកតំណាងគណបក្សទៅ ។ ការដែលបញ្ជូនតំណាងទៅនេះមិនមែនដើម្បីជ្រៀត ជ្រែកការងាររបស់អស់លោក ដែលមានសមត្ថកិច្ចទេ គឺគ្រាន់តែជាអ្នកទៅសង្កេតការណ៍ ប៉ុន្តែសមត្ថកិច្ចមិនទទួលយកទេ នេះជាបញ្ហា មួយដែលធ្វើឱ្យរាំងស្ទះ ។ ការដែលផ្តល់ប័ណ្ណព័ត៌មាននេះ គឺអស់លោកជាក្រុមប្រឹក្សាឃុំសង្កាត់លោកមិនបានបញ្ជាក់ពីអត្ថន័យនៃប័ណ្ណព័ត៌មានទេ គឺគាត់ចេះតចកទៅ ហើយគ្រាន់តែទារយកអត្តសញ្ញាណប័ណ្ណពីពលរដ្ឋទៅផ្ទៀងមើល ហើយចែកប័ណ្ណព័ត៌មានឱ្យដោយ មិនបានបញ្ជាក់ប្រាប់ប្រជាពលរដ្ឋថាប័ណ្ណនេះមានតម្លៃយ៉ាងណានោះទេ ។ ដូច្នេះប្រជាពលរដ្ឋខ្មែរ ដែលទទួលបានប័ណ្ណព័ត៌មាន មិនដឹង ថាជាប័ណ្ណអ្វីទេ ។ បញ្ហាមួយទៀតទាក់ទងទៅនឹងការត្រៀមចុះឈ្មោះបោះឆ្នោត លោក សោ ចាន់ដេត បានស្នើថាឱ្យមានរៀងរាល់ថ្ងៃ តែលោកប្រធានលេខាធិការដ្ឋានថាអត់ទេ ដោយមួយខែនេះច្រើនពេកហើយ ។ រយៈពេលមួយខែជាការចុះឈ្មោះ និង១១ ខែទៀតជា ការត្រៀមចុះឈ្មោះ ដូច្នេះបើនិយាយអញ្ចឹងហើយ សូមឱ្យអនុវត្តផង ។ សូមកុំឱ្យនិយាយផ្សេង ឯការអនុវត្តមិនទាន់មាន ដែលនាំឱ្យ ប្រជាពលរដ្ឋខ្មែរជាច្រើនអត់មានឈ្មោះបោះឆ្នោត ។ តួយ៉ាងនៅឆ្នាំ ២០០៣ តាមស្ថិតិមានប្រជាពលរដ្ឋជាង ១ លាននាក់អត់បាន ទៅបោះឆ្នោត ។ លោកមិនដឹងថានេះជាគោលបំណងរបស់ គជប ឬរាជរដ្ឋាភិបាលដើម្បីមិនឱ្យបោះទេ ។ ដូច្នេះសំណូមពរឱ្យលោក ប្រធានលេខាធិការដ្ឋាន និងអស់លោកនៅក្នុងទីនេះ ដែលមានសមត្ថកិច្ចទាំងអស់សូមឱ្យអនុវត្ត កុំឱ្យក្នុងពេលប្រជុំលើកឡើងមកល្អ ណាស់លោកសូមកោតសរសើរ ។ បើសិនជាស្រុកខ្មែរបានឱ្យអនុវត្ត មិនបាច់បានដល់ថ្នាក់និយាយទេ ត្រឹមតែអាចទទួលយកបានក៏ស្រុកខ្មែរ នឹងរីកចម្រើន មិនមែនដូចសព្វថ្ងៃនេះនៅតាមស្រុក ស្រែឃើញថាជីវភាពប្រជាជនលំបាកវេទនាណាស់ ។ សូមឱ្យអស់លោកដែលនៅទីនេះ បើសិនមានពេលទំនេរអាចដើរទស្សនៈកិច្ចនៅតាមស្រុកស្រែ និងជនបទដាច់ស្រយាលទើបដឹងថាខ្មែរក្រ ហើយវេទនាយ៉ាងណា ហើយភាពក្រីក្រនេះនឹងធ្លាក់ដល់អស់លោកដែល មានវត្តមាននៅទីនេះជាមិនខាន ។

លោក **ឱក សេរីសោភ័ក្ត្រ** ក្រោយពីបានស្តាប់ប្រសាសន៍របស់អស់លោក និងលោកស្រីមក គួរឱ្យសរសើរ គជប មែនទែនដែលរៀបចំប័ណ្ណព័ត៌មាននេះឡើង ។ បើសិនជា គជប មិនរៀបប័ណ្ណព័ត៌មាននេះ នឹងមានបញ្ហាច្រើនណាស់ដែលមើលមិនឃើញទេ ។ បញ្ហាដែលភូមិ ឃុំអនុវត្តក្នុងការចែកប័ណ្ណព័ត៌មានមើលមិនឃើញទេ ដូច្នេះបើសិនជា គជប មានបំណងមិនត្រង់ គជប មិនគួរបង្កើតការចែកប័ណ្ណព័ត៌មាននេះនាំឱ្យមានបញ្ហាទេ ។ ដោយសារ គជប បង្កើតការចែកប័ណ្ណនេះមកនាំឱ្យយើងទាំងអស់គ្នាឃើញថា យន្តការមាន

តម្លាភាព ចំណែកតិរិយាបថបុគ្គលនៅថ្នាក់មូលដ្ឋានជារឿងបុគ្គល ដែលគួរតែចែកឱ្យដាច់ពីគ្នា ចៀសវាងការរើផ្ដើលតអញ្ចឹងមិនបានទេ ហើយការចែកប័ណ្ណព័តិមាននេះក្រសួងមហាផ្ទៃក៏អនុញ្ញាតិ ក្រសួងមហាផ្ទៃក៏ធ្វើ ហើយគណបក្សទាំងអស់ដែលជាសមាភាពក៏ចូលរួមទៀត ។ ក្រោយពីបានស្ដាប់លោក សួន ចំរើន លោកសូមសរសើរដល់ គជប ដោយស្មោះ ដែលធ្វើការចែកប័ណ្ណព័តិមាន ហើយធ្វើឱ្យយើង មើលឃើញអាកប្បកិរិយាអាជ្ញាធរនៅតាមមូលដ្ឋាន ។

លោក **សឹង សារឿម** មកពីអង្គការ ក្រុមអភិវឌ្ឍន៍ភូមិប្រចាំខេត្តបាត់ដំបង លើកបញ្ហាមួយចំនួនដែលទាក់ទង នឹងបញ្ហាដំណើរការបោះឆ្នោត គឺការចុះឈ្មោះ និងការផ្ដល់ប័ណ្ណព័តិមានបោះឆ្នោត ។ តាមមតិមួយចំនួនសូមឱ្យ គជប ពន្យាពេលដើម្បីឱ្យប្រជាពលរដ្ឋចុះឈ្មោះ និងទទួលព័តិមានឱ្យបានគ្រប់ៗគ្នា ។ តាមចម្លើយរបស់លោកប្រធាន គខប ថាការពន្យាពេលមិនអាចបានទេ បានតែមួយខែ ក្រោយមកក្រុមការងារត្រូវយកការងារនេះទៅដល់ស្មៀនឃុំ ដើម្បីទទួលបន្ថែមចំពោះប្រជាពលរដ្ឋដែលមិនទាន់បានទទួលព័តិមាន ក៏ដូចជាប័ណ្ណព័តិមានសម្រាប់ការបោះឆ្នោត ។ តាមគំនិតលោកផ្ទាល់ប្រហែលជាអាចមានបញ្ហា ត្រង់ថាប្រជាពលរដ្ឋសព្វថ្ងៃអត់ទាន់យល់ដឹងអំពីតំលៃនៃការបោះឆ្នោតសម្រាប់ខ្លួនគាត់ទេ អញ្ចឹងប្រជាពលរដ្ឋមិនអាចធ្វើដំណើរពីភូមិរបស់គាត់មកសាលាឃុំបានទេ ដោយសារបញ្ហាចំណាយ និងការយល់ដឹងផងប្រហែលជាមិនអាចទេ ។ ការបង្កើតច្បាប់គួរតែតម្រូវទៅតាមស្ថានភាពការងារដែរ ឧបមាបើយើងចង់កាត់អាវត្រូវគិតពីទំហំមនុស្សដែរ បើមនុស្សធំមិនអាចកាត់អាវតូចបានទេ ហើយច្បាប់ក៏ត្រូវអញ្ចឹងដែរត្រូវតែតម្រូវទៅតាមការងារ បើការងារធ្វើមួយខែអត់ចប់ ច្បាប់តម្រូវការងារមួយខែម្ដេចកើត ត្រូវតម្រូវការងារឱ្យលើសពីមួយខែ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ ហើយការងារចប់ចុងចប់ដើម ។ ដូច្នេះសំណូមពរថា ច្បាប់ធ្វើយ៉ាងណាឱ្យសមទៅតាមទំហំនៃការងារ កាត់អាវឱ្យសម នឹងមាឌមនុស្ស ។

**លោក ប៉ា ប៊ុនហ៊ាង** ប្រធានការិយាល័យគណបក្ស សមរង្ស៊ី ខេត្តបាត់ដំបង លោកមានវាសនាដោយបានជួបលោក ឱក សេរីសោភ័ក្តិ ជាលើកទី២ ។ ក្នុងថ្ងៃនេះលោកសូមរក្សាជំហររបស់លោកដដែល ក្នុងបញ្ហាទី១ អំពីការដែលព្រះសង្ឃបោះឆ្នោត ។ លោក មានអារម្មណ៍ភ្ញាក់ផ្អើលមែនទែនដោយលោកបណ្ឌិត ហេង មណីចិន្តា លើកអំពីបញ្ហាវត្ត ។ លោកសូមរាយការណ៍ក្នុងបញ្ហានេះ ដោយដាក់ចំណងជើង " ជិតហើយឆ្ងាយវិញ" ព្រោះឆ្នាំ ១៩៩៣ ពេលដែលអ៊ុនតាក់ចូលមកបោះឆ្នោតនៅប្រទេសកម្ពុជា ឃើញថាព្រះសង្ឃមានសិទ្ធិបោះឆ្នោតទាំងអស់ ដោយពេលនោះការិយាល័យបោះឆ្នោតត្រូវបានបង្កើតនៅតាមវត្ត នេះជាឱកាសមួយដើម្បីឱ្យព្រះសង្ឃបានបោះឆ្នោតទាំងអស់ ។ តែអកុសលមកដល់ការបោះឆ្នោតមេឃុំ ២០០២ និងបោះឆ្នោតតំណាងរាស្ត្រ ២០០៣ សម្ដេចសង្ឃគណៈមហានិកាយចេញប្រកាសថា លោកសង្ឃត្រូវចេញឱ្យឆ្ងាយពីបញ្ហាបោះឆ្នោត និងនយោបាយ ដូច្នេះធ្វើឱ្យមានការរអាក់រអួល ដោយអាចារ្យវត្តទាំងអស់ទូទាំងប្រទេសបង្ករលក្ខណៈមួយរាំងស្ទះដល់ព្រះសង្ឃមិនឱ្យចេញទៅបោះឆ្នោត ។ តាំងពីពេលនោះមកការិយាល័យ បោះឆ្នោតអត់មាននៅតាមវត្តទៀតទេ ដូច្នេះជាការអយុត្តិធម៌មួយ ព្រោះសង្គមមួយសមាភាពប្រជាពលរដ្ឋមាន តាំងពី ព្រះសង្ឃ មន្ត្រី រាជការ និងប្រជាជនជាដើម តែដោយឡែកព្រះសង្ឃមិនមានសិទ្ធិចេញទៅបោះឆ្នោតជាលក្ខណៈមួយអយុត្តិធម៌ ។ ដោយយោងតាម សម្ដីអាចារ្យម្នាក់នៅវត្តពោធិ៍វាល ថា "វត្តធ្វើសម្រាប់ព្រះសង្ឃនៅ និងសហគមន៍ប្រើការខ្លះ បើវត្តធ្វើហើយមិនឱ្យគេបោះឆ្នោត ហាក់ដូចជាធ្វើឱ្យខ្មែរនៅ" ។ ដូច្នេះលោកសោកស្ដាយណាស់ ហើយសូមឱ្យមានតាមវត្តវិញដើម្បីឱ្យព្រះសង្ឃបានបោះឆ្នោត ។ នេះជាសំណូមពរជាលើកទី២ ហើយលោកសេរីសោភ័ក្តិ នៅតែជំពាក់ដដែល លើកទី១ នៅ FMI ។

**លោក ឱក សេរីសោភក្តិ** ខប់សែលបានធ្វើការអន្តរាគមន៍ហើយ ហើយឥឡូវព្រះសង្ឃមិនមានបញ្ហាអ្វីទៀតទេក្នុងការបោះឆ្នោត ។ គណៈសង្ឃទាំងពីរបើកសិទ្ធិទូលាយហើយ ឯកឧត្តមអឹម សួស្តី ក៏មានប្រសាន៍ យើងបានជជែកនៅថ្នាក់ជាតិ ឥឡូវនេះព្រះសង្ឃមិនដូច ២០០២ និង២០០៣ ទេ ហើយមិនមានចេញសង្ឃដីការហាមឃាត់ទៀតទេ ។ បញ្ហានេះខប់សែលបានប្រកាសនៅគ្រប់ខេត្តទាំងអស់ហើយ ។ ព្រះសង្ឃនៅរតនៈគីរី និងមណ្ឌលគីរីបានមានពុទ្ធិការសួរអំពីបញ្ហានេះ ហើយខប់សែលក៏បានឆ្លើយជូនហើយ ហើយនឹងឆ្លើយជូននៅពេលនេះច្បាស់តែម្តងថា ឥឡូវនេះបើកទូលាយហើយមិនមានបញ្ហានេះទៀតទេ ។

លោក **សោម វីរៈតារា** នាយកអង្គការ CDK ខេត្តបាត់ដំបង ក្នុងនាមជាអង្គការមួយក្នុងខេត្តបាត់ដំបង លោកសូមជម្រាបសួរដល់លេខាធិការដ្ឋានខេត្តរៀបចំការបោះឆ្នោត

ទី១. តើធ្វើដូចម្តេចឱ្យការបោះឆ្នោតមានតម្លាភាព ក្នុងកិច្ចពិភាក្សាកន្លងមកមួយព្រឹកនេះ តាមដំណើរការបោះឆ្នោតកន្លងមកជាច្រើន រហូតដល់ការត្រៀមបោះឆ្នោតអណ្តតិខាងមុខ?

ទី២. តើធ្វើយ៉ាងណាឱ្យមានទំនុកចិត្តពីប្រជាពលរដ្ឋក្នុងការបោះឆ្នោត និងមិនមានការគម្រាមគំហែង?

ទី៣. តើធ្វើយ៉ាងម៉េចដើម្បីកាត់បន្ថយនូវអាកប្បកិរិយារបស់មេភូមិ ក្នុងនីតិវិធីសម្របសម្រួលនៅថ្នាក់ភូមិ ស្តីពីការចុះឈ្មោះបោះឆ្នោត និងធ្វើយ៉ាងណាដើម្បីដោះស្រាយនីតិវិធីនៅពេលដែលកើតឡើងនូវអាកប្បកិរិយារបស់មេភូមិនៅក្នុងពេលបោះឆ្នោតខាងមុខ ។

ទី៤. តើប្រជាពលរដ្ឋដែលមិនមានឈ្មោះបោះឆ្នោត គជប ដោះស្រាយ ឬសម្របសម្រួលឱ្យប្រជាជនយ៉ាងម៉េចដែរក្នុងនីតិវិធីបោះឆ្នោតនៅពេលខាងមុខនេះ ។

លោក **ឱក សេរីសោភក្តិ** អ្វីដែលលោក សោម វីរៈតារា សួរគឺយើងទាំងអស់គ្នាកំពុងតែធ្វើនេះហើយ ។ ធ្វើយ៉ាងណាឱ្យមានតម្លាភាព គឺយើងយកបញ្ហាទាំងអស់មកដាក់លើតុឱ្យមើលគ្រប់គ្នា ដោយមិនមានការលាក់លៀម ។ លោកប្រធាន គខប ឱ្យសិក្ខាកាមទាំងអស់គ្នាទិះទៀនមួយព្រឹកហើយ នេះហើយដែលជាដំណើរធ្វើឱ្យមានតម្លាភាព ។ ធ្វើដូចម្តេចដើម្បីឱ្យមានទំនុកចិត្តនឹងដោះស្រាយបញ្ហាប្រធានភូមិ គឺមានតែការចូលរួមទេ ដរាបណាយើងចូលរួមពិនិត្យមើលទាំងអស់គ្នា យើងកំពុងនិយាយថាមេភូមិធ្វើខុសហើយកន្លែងហ្នឹងហើយដែលយើងទុកចិត្ត ។ តើការទុកចិត្តរវាងអ្នកណាជាមួយអ្នកណា? គឺរវាងអ្នកបោះឆ្នោត និងអាជ្ញាធរ ការទុកចិត្តរវាងអ្នកបោះឆ្នោត និងលេខាធិការដ្ឋានរៀបចំការបោះឆ្នោត រវាងប្រជាពលរដ្ឋនិងអាជ្ញាធរ រវាងសង្គមស៊ីវិល និងគណបក្សនយោបាយដែលយើងកំពុងតែនិយាយមួយព្រឹកនេះហើយ ។ ការចូលរួម និងវប្បធម៌ជជែកគ្នានេះហើយដើម្បីជម្រុញឱ្យមានការទុកចិត្ត ។ សំណួរបងទាំងបួននេះហើយដែលជម្រុញឱ្យមានការទុកចិត្ត ។ តើធ្វើយ៉ាងណាដើម្បីឱ្យប្រជាពលរដ្ឋដែលមិនទាន់មានឈ្មោះ គឺខប់សែលកំពុងតែធ្វើនេះហើយ ។ យន្តការខប់សែលកំពុងតែជម្រុញថា ហេតុអ្វីបានជាប្រជាជនចុះឈ្មោះអត់បាន? យើងទាំងអស់គ្នានិយាយមួយព្រឹកនេះហើយគឺជាការឆ្លើយតបជូនបងទាំងអស់ ។ ប្រជាពលរដ្ឋមិនបានចុះឈ្មោះដោយសារការចាកចេញទៅរកស៊ី ដូច្នេះកុំទាន់បិទត្រឹមមួយខែ បន្តទៅមុខទៀត ។ ចុះឈ្មោះ ២០ ថ្ងៃតិចពេកគួរបន្តទៅទៀត ហើយបើសិនតិចពេកតើយើងគួរប្រើរយៈពេលចុះឈ្មោះត្រៀម ៩ ខែនេះបានគ្រប់សព្វទេ ។ ជួនកាលយើងមើលឃើញកំហុស គខប និងក្រុមប្រឹក្សាឃុំសង្កាត់ច្រើន តើតួនាទីយើងជាប្រជាពល

រដ្ឋបានប្រើយន្តការនេះទេ? ទាល់តែចូលរួមទាំងអស់គ្នាទើបទៅរួច កាលណាយើងមើលឃើញតែកំហុសរបស់អាជ្ញធរ ហើយរំលងការទទួលខុសត្រូវក្នុងកាតព្វកិច្ចជាប្រជាពលរដ្ឋក៏មានការពិបាកដែរ ។

លោក **វ៉ន ពន** សូមបញ្ជាក់ពីការសុំពន្យាពេលចុះឈ្មោះបោះឆ្នោត ក្នុងច្បាប់បានចែងហើយថា "ពីថ្ងៃទី ០១ ដល់ ២០ តុលា រៀងរាល់ឆ្នាំ" នេះជាច្បាប់ ។ ហេតុអ្វីពុំអាចនឹងបន្ថែមពីការចុះឈ្មោះនេះទៅបាន ព្រោះអ្នកដែលត្រូវចុះឈ្មោះថ្មីនៅតាមឃុំនីមួយនៅមានសល់តិច គឺអ្នកដែលអត់ទាន់បានចុះ និងអ្នកដែលគ្រប់អាយុ ។ មួយទៀតដោយសារបញ្ហាថវិកា គម្រោងថវិកាតែ ២០ ថ្ងៃទេ ដោយយោងទៅលើចំនួនអ្នកចុះឈ្មោះនៅសល់តិចពីមួយឆ្នាំទៅមួយឆ្នាំ ។ ដូច្នេះសំណូមពររបស់អស់លោកសមស្របហើយ បើសិនជាថ្ងៃចុះឈ្មោះកើនឡើង លោកដែលជាប្រធានក៏បានកើនប្រាក់ថ្ងៃដែរ ។ ប៉ុន្តែច្បាប់បានកំណត់យ៉ាងដូច្នេះ ដោយសារបញ្ហាថវិកា ។ បញ្ហា គ្មានតម្លាភាព ការរាប់សន្លឹកឆ្នោតនៅតាម គឃប ខ្លះគេថាល្អ ខ្លះថានៅតាមការិយាល័យមានតម្លាភាព ។ សូមអស់លោកពិចារណា ថា តាមការិយាល័យមានតម្លាភាពយ៉ាងម៉េច ហើយមានការលំបាក និងល្អយ៉ាងម៉េចដល់ប្រជាពលរដ្ឋ ។

លោក **ឱក សេរីសោភ័ក្តិ** ថ្ងៃនេះយើងពិតជាមានសេចក្តីរីករាយណាស់ដែលបានមានវត្តមាននៅទីនេះ ហើយមានអ្នកកាសែតចង់ផ្សព្វផ្សាយពីការប្រជុំនេះ អាចផ្សព្វផ្សាយបាន ព្រោះខប់សែលមិនមានលក្ខណៈ សំងាត់ទេ ។ សុំបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំនេះមានសមាជិកជាង ១០០ នាក់ ហើយសុទ្ធតែថតខ្សែរអាត់ទៀត ដូច្នេះបើសិនជាយកទៅផ្សព្វផ្សាយសូមឱ្យមានបរិបទត្រឹមត្រូវ ព្រោះជួនកាលអ្នកកាសែតពិបាកណាស់ព្រោះពេល និងទំព័ររបស់គាត់តិច ដូច្នេះគាត់ច្បិច ជួនកាលចុះមិនអស់សេចក្តីនាំឱ្យមានការបកស្រាយ ។ អ្នកកាសែតគឺជាវិជ្ជាជីវៈមួយដែលលោកគោរពស្ញប់ស្ញែងមែនទែន ជាពិសេស អ្នកកាសែតក្នុងស្រុក ថ្ងៃក្រោយប្រជាធិបតេយ្យមានជីវិតបានដោយសារអ្នកសារព័ត៌មាន មានសីលធម៌ ដើម្បីឱ្យប្រជាពលរដ្ឋគោរព បានលុះត្រាតែអ្នកកាសែតគោរពសីលធម៌ជាអ្នកកាសែត ។ ដូច្នេះអញ្ជើញចុះបាន តែសូមឱ្យមានសីលធម៌ ព្រោះអ្វីៗសុទ្ធតែមាននៅក្នុងខ្សែរអាត់ ។

លោក **Larry Stange** ជាថ្មីម្តងទៀតលោកសូមសម្តែងការរីករាយណាស់ដែលបានមកចូលរួមតាំងពីពេលនេះមកដល់ចប់ ហើយសូមជូនសេចក្តីសរុបបញ្ចប់នៃកិច្ចប្រជុំខប់សែលប្រ៉មនាព្រឹកនេះ ។ លោកសូមលើកបីចំណុចដែលអស់លោក លោកស្រីបានលើកក្នុងព្រឹកនេះ ។ ទី១. លោកបានទៅក្រុងប៉ៃលិន មានអ្នកស្រីម្នាក់បានលើកឡើងថា កិច្ចប្រជុំខប់សែលនេះគឺជាការបង្ហាញពីការចាស់ចិត្តចាស់គំនិតនៃលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដូច្នេះនេះជាចំណុចមួយដែលលោកចាប់អារម្មណ៍ ។ ចំណុចនេះមួយហើយដែលវិទ្យាស្ថាន CDRI ជាពិសេសតាមរយៈយន្តការខប់សែលនេះ ខំប្រឹងធ្វើយ៉ាងណាដើម្បីជម្រុញឱ្យមានការពិភាក្សាមួយប្រកបដោយលទ្ធិប្រជាធិបតេយ្យបើកទូលាយ និងចំហរ ។ បីចំណុចដែលលោកចាប់អារម្មណ៍ ១. ការធ្វើអត្តសញ្ញាណប័ណ្ណជាតិ ២. ការចែកប័ណ្ណព័ត៌មានជូនអ្នកបោះឆ្នោត ៣. បរិយាកាសនយោបាយដែលបានលើកឡើងអំពីការខ្លាចរអារនឹងការគំរាមគំហែង និងការប្រកាន់បក្សពួកជាដើម ។ លោកសូមសរសើរដោយស្មោះស្ម័គចំពោះគុណភាពនៃការពិភាក្សានៅព្រឹកនេះ ដែលជាការបង្ហាញពីការចាប់ផ្តើមមួយដែលយើងកំពុងតែធ្វើ ឱ្យមានលិទ្ធិប្រជាធិបតេយ្យប្រកបដោយចាស់ចិត្តចាស់គំនិតនេះ ។

ចំណុចនេះលោកសូមបញ្ចប់ដោយគ្រាន់តែបង្ហាញថាក្នុងនាមលោកជាជនបរទេស ជនជាតិអូស្ត្រាលីដែលទើបតែមកធ្វើការនៅស្រុកខ្មែរជាង២ឆ្នាំនេះ លោកបានបញ្ជាក់ថា ប្រទេសអូស្ត្រាលីគឺជាប្រទេសមួយដែលមានអាយុកាលប្រហែលជា១០០ ឆ្នាំទេ ប៉ុន្តែ

ពោរពេញទៅដោយការអនុវត្តន៍លិទ្ធិប្រជាធិបតេយ្យដ៏រឹងមាំ និងចាស់ចិត្តចាស់គំនិត ហើយទទួលបានការកោតសរសើរពីមជ្ឈដ្ឋានទូទាំងពិភពលោកផងដែរ ។

មួយទៀតដំណើរការនៅក្នុងការដែលធ្វើឱ្យរដ្ឋធម្មនុញ្ញប្រកបដោយលិទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅប្រទេសអូស្ត្រាលី ក្នុងពេលសព្វថ្ងៃនេះ គឺទាមទារពេលវេលាជាច្រើនទសវត្សរ៍ ដើម្បីកសាងពីមួយដំណាក់កាលទៅមួយដំណាក់កាលធ្វើយ៉ាងណាដើម្បី ឱ្យធម្មនុញ្ញនៃលិទ្ធិប្រជាធិបតេយ្យនេះមានពិតប្រាកដនៅក្នុងប្រទេស ។ កាលដែលកសាងបាននូវធម្មនុញ្ញប្រកបដោយលិទ្ធិប្រជាធិបតេយ្យបាន ដោយសារមានការចូលរួមយ៉ាងខ្លាំងជាពិសេសការឯកភាពគ្នានៅក្នុងសង្គម ទាំងផ្នែកសហគមន៍ ភាគីពាក់ព័ន្ធនានា គណបក្សនយោបាយ ដើម្បីធ្វើយ៉ាងណាជួយជម្រុញឱ្យការឯកភាពនេះឆ្ពោះទៅរកលិទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ ពេលនេះលោកសូមលើកឡើងម្តងទៀតសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រ ចំពោះការចូលរួមរបស់លោកស្រី អស់លោក ក្នុងការលើកឡើងពិភាក្សាគ្នា ដើម្បីជាចំណុចមួយដែលយើងអាចបង្ហាញថា នេះជាដំណើរការមួយដែលយើងកំពុងតែវិវត្តនទៅរកការកសាងលិទ្ធិប្រជាធិបតេយ្យមួយដ៏ចាស់ចិត្តចាស់គំនិត ។

ជាចុងក្រោយលោកសូមថ្លែងអំណរគុណចំពោះការចូលរួមនៅក្នុងការពិភាក្សារបស់អស់លោក លោកស្រី នៅក្នុងព្រឹកនេះដែលការចូលរួមនេះគឺជាជំហ៊ានមួយឆ្ពោះទៅរកការកសាងលិទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដ ។